# នគរបាល
# ព្រះរាជាណាចក្រកម្ពុជា



## ២០០៥

សន្តិសុខ ការអភិវឌ្ឍន៍
និងកិច្ចសហប្រតិបត្តិការអន្តរជាតិ

# នយោបាយការពារជាតិ
# នៃព្រះរាជាណាចក្រកម្ពុជា
# ឆ្នាំ២០០៦



ខ្ញុំធ្លាប់បានរំលឹកជារឿយៗថា សៀវភៅ ស ការពារជាតិ គឺជាត្រីវិស័យសំរាប់កងយោធពលខេមរភូមិន្ទ ក្នុងការអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាលនៅលើវិស័យការពារជាតិ ឱ្យបានសំរេចគោលដៅជាស្ថាពរ ។ ជាក់ស្តែង មុំមួយនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ទាមទារនូវការឆ្លើយតបយ៉ាងមានប្រសិទ្ធិភាពពីសំណាក់កងយោធពលខេមរភូមិន្ទ នៅក្នុងការកែទំរង់របស់ខ្លួន ដើម្បីធានាឱ្យបានទាំងស្រុងនូវសន្តិភាព ស្ថិរភាព សន្តិសុខ អធិបតេយ្យភាព បូរណភាពទឹកដី និងការអភិវឌ្ឍន៍ប្រទេសជាតិ ។ លើសពីនេះទៅទៀត កងយោធពលខេមរភូមិន្ទគឺជាកំលាំងឈានមុខគេ នៅក្នុងការលើកតំកើងកិត្យានុភាពរបស់កម្ពុជា នៅលើឆាកអន្តរជាតិ តាមរយៈការចូលរួមក្នុងបេសកកម្មសន្តិភាព និងមនុស្សធម៌ នៅក្នុងក្របខ័ណ្ឌនៃសំណូមពររបស់អង្គការសហប្រជាជាតិ ។

ដើម្បីជោគជ័យ ខ្ញុំសូមអំពាវនាវឱ្យមានការប្រឹងប្រែងអនុវត្តឱ្យបានពេញលេញនូវគោលនយោបាយទាំងឡាយដែលមានចែងនៅក្នុងឯកសារដ៏មានសារៈសំខាន់នេះ ទាំងនៅក្នុងមជ្ឈដ្ឋានកងយោធពលខេមរភូមិន្ទ ក៏ដូចជាការជំរុញឱ្យមានស្មារតីសហការទ្វេឡើងថែមទៀត ពីសំណាក់ស្ថាប័នជាតិ និងអន្តរជាតិនានា ដែលពាក់ព័ន្ធ ។

ខ្ញុំសូមកោតសរសើរ ហើយសង្ឃឹមថា សៀវភៅ ស ការពារជាតិ ឆ្នាំ២០០៦ នេះ នឹងក្លាយទៅជាមាគ៌ានយោបាយយុទ្ធសាស្ត្រដ៏ចំបង សំរាប់ការបំពេញតួនាទី និង ភារៈកិច្ចរបស់កងយោធពលខេមរភូមិន្ទ នៅក្នុងការកសាង និងការពារមាតុភូមិអង្គរ នៃយើង ។

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**



កងយោធពលខេមរភូមិន្ទមានតួនាទីចំបង នៅក្នុងការការពារអធិបតេយ្យភាព ឯករាជ្យភាព និងបូរណភាពទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងរួមចំណែកនៅក្នុងការធានានូវស្ថិរភាព សុវត្ថិភាព និងសន្តិសុខ ដែលជាតម្រូវការចាំបាច់បំផុត ហើយក៏ជាមូលដ្ឋានដ៏ចំបង នៅក្នុងការធានាឱ្យមានការអភិវឌ្ឍន៍ប្រទេសជាតិនៅគ្រប់វិស័យ ។ គ្មានកាលៈទេសៈណាមួយ ដែលការរស់នៅបានប្រកបដោយភាពសុខដុមរមនា និងមានវិបុលភាព ដោយគ្មានស្ថិរភាព និងសន្តិសុខនោះទេ ។ ស្ថិរភាព និងសន្តិសុខនៅក្នុងសង្គមជាតិមួយ រួមចំណែកផ្តល់នូវសន្តិភាពសំរាប់តំបន់ ក៏ដូចជាសំរាប់ពិភពលោកទាំងមូលផងដែរ ។

យើងទាំងអស់គ្នាទទួលស្គាល់ដោយឥតកែប្រែ និងគោរពជានិច្ចចំពោះនយោបាយ **ឈ្នះ ឈ្នះ** របស់សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ថាជាវិធានការយុទ្ធសាស្ត្រតែមួយគត់ដែលមានប្រសិទ្ធិភាពបំផុត សំរាប់ការបង្រួបបង្រួមជាតិ ការបញ្ចប់ទាំងស្រុងនូវទុក្ខវេទនារបស់ប្រជាពលរដ្ឋខ្មែរ និងនាំព្រះរាជាណាចក្រកម្ពុជាឆ្ពោះទៅរកការអភិវឌ្ឍន៍ នៅគ្រប់វិស័យ ។

យុទ្ធជន យុទ្ធនារីនៃកងយោធពលខេមរភូមិន្ទបានធ្វើពលិកម្មច្រើនឥតគណនានៅក្នុងយុទ្ធនាការអនុវត្តនយោបាយ **ឈ្នះ ឈ្នះ** នេះ។ គឺអ្នកទាំងអស់នោះហើយដែល

បានជួយបង្កលក្ខណៈឱ្យមានបរិយាកាសសន្តិភាព និងសេចក្តីសង្ឃឹមដ៏ភ្លឺថ្លា នាពេលបច្ចុប្បន្ន ក៏ដូចជាតទៅថ្ងៃអនាគត ។ ក្រៅពីភារៈកិច្ចធានាឱ្យបានទាំងស្រុងនូវនិរន្តរភាពនៃសន្តិភាព ស្ថិរភាព និងសន្តិសុខ ជូនប្រទេសជាតិ កងយោធពលខេមរភូមិន្ទមានការទទួលខុសត្រូវជាច្រើនទៀត រួមទាំងការចូលរួមក្នុងការស្តារ និងកសាងជាតិ និងបេសកកម្មអន្តរជាតិ ផងដែរ ។

ទន្ទឹមនឹងការពុះពារឧបសគ្គដ៏ស្មុគ្រស្មាញនៅក្នុងដំណើរការកែទំរង់របស់ខ្លួន កងយោធពលខេមរភូមិន្ទកំពុងលើកស្ទួយកិត្យានុភាពរបស់ព្រះរាជាណាចក្រកម្ពុជា នៅលើឆាកអន្តរជាតិ ហើយដែលមិនធ្លាប់មាននៅក្នុងប្រវត្តិសាស្ត្ររបស់កម្ពុជា ។

ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ការសំរេចជាស្ថាពរនូវគោលដៅនៃកិច្ចការពារជាតិ ជោគជ័យនៃការកែទំរង់កងយោធពលខេមរភូមិន្ទ និងអនាគតដ៏មានអត្ថន័យរបស់យើង ពឹងផ្អែកជាចំបងទៅលើមាគ៌ានយោបាយប្រកបដោយភាពប្រាកដនិយមមួយ ។ ដូច្នេះ សៀវភៅ ស ការពារជាតិ ឆ្នាំ២០០៦ គឺជាត្រីវិស័យ និងជាផែនទីបង្ហាញផ្លូវ សំរាប់យើងទាំងអស់គ្នា ធ្វើដំណើរឆ្ពោះទៅកាន់គោលដៅទាំងនោះ ។

រាជធានីភំពេញ ថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៦

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**ទៀ បាញ់**

# មាតិកា

អារម្ភកថា

## ជំពូកទី ១
## ការពិនិត្យឡើងវិញ នូវគោលនយោបាយការពារជាតិ
## នៃសៀវភៅ ស ការពារជាតិ ឆ្នាំ២០០០


| | |
|---|---|
| គោលដៅនៃកិច្ចការពារជាតិ | ១ |
| អាទិភាពនៃកិច្ចការពារជាតិ | ៣ |
| យុទ្ធសាស្ត្រយោធា | ៦ |
| លទ្ធផលនៃការអនុវត្តនីវិធានការយុទ្ធសាស្ត្រ | ៧ |


## ជំពូកទី ២
## ការវិភាគអំពីការគំរាមកំហែង
## មកលើសន្តិសុខនៃព្រះរាជាណាចក្រកម្ពុជា


| | |
|---|---|
| អំពើភេរវកម្មអន្តរជាតិ និងនៅក្នុងតំបន់ | ១៥ |
| អំពើភេរវកម្ម និងសន្តិសុខនៃប្រទេសកម្ពុជា | ១៦ |
| សន្តិសុខសង្គម | ២០ |
| ផលវិបាកផ្នែកភូមិសាស្ត្រ | ២៣ |
| បញ្ហាផ្នែកប្រជាសាស្ត្រ | ២៥ |
| បញ្ហាសេដ្ឋកិច្ច | ២៦ |
| បញ្ហាបរិស្ថាន | ២៩ |

## ជំពូកទី ៣

## យុទ្ធសាស្ត្រ ២០០៦


| | |
|---|---|
| ក្របខ័ណ្ឌនៃយុទ្ធសាស្ត្រ ២០០៦ | ៣១ |
| គោលដៅយុទ្ធសាស្ត្រ ២០០៦ | ៣៤ |
| យុទ្ធសាស្ត្រយោធា ២០០៦ | ៣៧ |
| អាទិភាពសំរាប់កិច្ចការពារជាតិ ២០០៦ | ៣៨ |
| តួនាទីរបស់កងយោធពលខេមរភូមិន្ទ | ៤០ |


## ជំពូកទី ៤

## ផែនការយុទ្ធសាស្ត្រ ២០០៦


| | |
|---|---|
| កិច្ចការពារព្រំដែន | ៤១ |
| សមត្ថភាពប្រឆាំងអំពើភេរវកម្ម | ៤៣ |
| សន្តិសុខដែនសមុទ្រ | ៤៧ |
| សមត្ថភាពប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន | ៥២ |
| អព្យាក្រឹតផ្នែកនយោបាយរបស់កងយោធពលខេមរភូមិន្ទ | ៥៧ |
| ការកាត់បន្ថយកំលាំងទ័ព | ៥៨ |
| ការកសាងកំលាំងទ័ព | ៦០ |
| ការកែសំរួលរចនាសម្ព័ន្ធ និងការិយាធិបតេយ្យ | ៦៣ |
| ការកែទំរង់វិស័យអប់រំហ្វឹកហ្វឺន | ៦៤ |
| ការកែទំរង់ប្រព័ន្ធភស្តុភារ-ហិរញ្ញវត្ថុ | ៦៥ |
| ការលើកស្ទួយជីវភាពរបស់យោធិន | ៧០ |

ការថែទាំគ្រឿងយុទ្ធោបករណ៍ ៧១
បន្ទាយទ័ព ៧៤
កិច្ចប្រឹងប្រែងជួយខ្លួនឯង ៧៥
បច្ចេកវិទ្យាពត៌មាន ៧៦
កិច្ចប្រតិបត្តិការជួយសង្គ្រោះ ៧៧
តំរូវការក្របខ័ណ្ឌច្បាប់ ៧៩
កិច្ចសហប្រតិបត្តិការអន្តរជាតិ ៨២
សមត្ថភាពក្នុងកិច្ចប្រតិបត្តិការរក្សាសន្តិភាព ៨៤

## ជំពូកទី ៥
## យន្តការនៃអភិបាលកិច្ច

តម្លាភាព ៨៧
ការឃ្លាំមើលលើការជឿនលឿនទៅមុខ ៨៩
ការទទួលខុសត្រូវចំពោះការអនុវត្តន៍ ៩១

*រូបភាពក្រៅ: ប្រាសាទបាយ័ន ឬអង្គរធំ ដែលកសាងដោយក្សត្រខ្មែរ គឺព្រះបាទជ័យវរ្ម័នទី៧ នៅសតវត្សទី១៣ ។*

# អារម្ភកថា

នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ទិដ្ឋភាពផ្នែកសន្តិសុខរបស់ព្រះរាជាណាចក្រកម្ពុជាមានការផ្លាស់ប្តូរ ដោយសារឥទ្ធិពលនៃការវិវត្តន៍របស់សភាពការណ៍សន្តិសុខពិភពលោក និងនៅក្នុងតំបន់ ។ ផ្តើមចេញពីនយោបាយ **ឈ្នះ ឈ្នះ** និងស្មារតីផ្សះផ្សាជាតិរបស់រាជរដ្ឋាភិបាល ដែលមានសម្តេច **ហ៊ុន សែន** ជាប្រមុខ វិបត្តិផ្ទៃក្នុងដែលញាំញី និងបំផ្លិចបំផ្លាញប្រទេសជាតិអស់រយៈពេលជាច្រើនទសវត្សរ៍ ត្រូវបានបញ្ចប់ទាំងស្រុង ។ តែទោះយ៉ាងនេះក្តី កម្ពុជានៅតែប្រឈមមុខនឹងការដោះស្រាយបញ្ហាធំៗដែលមិនមែនជាប្រពៃណីមួយចំនួនទៀត មានជាអាទិ៍ អំពើភេរវកម្មអន្តរជាតិ និងឧក្រិដ្ឋកម្មឆ្លងដែន ហើយដែលកំពុងគំរាមកំហែងដល់សន្តិសុខ និងការអភិវឌ្ឍន៍ របស់ប្រទេសជាតិ ។

នៅក្នុងកិច្ចខិតខំរបស់ខ្លួន ដើម្បីធ្វើសមាហរណកម្មចូលទៅក្នុងសហគមន៍អន្តរជាតិ កម្ពុជាបានបំពេញនូវករណីយកិច្ចយ៉ាងច្រើនសំរាប់ផលប្រយោជន៍រួមរបស់ប្រជាជាតិទាំងនៅក្នុងតំបន់ ក៏ដូចជាពិភពលោក ។ ប្រទេសកម្ពុជាបានធ្វើកិច្ចសហប្រតិបត្តិការយ៉ាងពេញទំហឹងនៅក្នុងវិស័យជាច្រើន ក្នុងនោះមានរួមទាំងវិស័យសន្តិសុខផងដែរ ។ រាជរដ្ឋាភិបាលបានប្តេជ្ញាចិត្តយ៉ាងមុះមុតនៅក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើភេរវកម្ម ។ ឆន្ទៈនេះឆ្លុះបញ្ចាំងឱ្យឃើញតាមរយៈវិធានការធំៗមួយចំនួន ដែលរាជរដ្ឋាភិបាលកម្ពុជាប្រកាន់យក មិនត្រឹមតែដើម្បីសន្តិសុខ និងភាពសុខដុមរមនារបស់ប្រជាពលរដ្ឋកម្ពុជាប៉ុណ្ណោះទេ តែក៏សំរាប់សេចក្តីសុខ និងផលប្រយោជន៍រួម សំរាប់តំបន់ និងពិភពលោកផងដែរ ។

ក្រោយពេលដែលមានសន្តិភាពពេញលេញចាប់តាំងពីចុងឆ្នាំ១៩៩៨មក កម្ពុជាបានតស៊ូដើម្បីពង្រឹងស្ថិរភាព សន្តិសុខផ្ទៃក្នុង សំរាប់ជាមូលដ្ឋានរឹងមាំនៅក្នុងការស្តារ និងកសាងប្រទេសជាតិឡើងវិញ ។ កងយោធពលខេមរភូមិន្ទគឺជាកំលាំងដ៏សំខាន់នៅក្នុងការអនុវត្តន៍នយោបាយរបស់រាជរដ្ឋាភិបាល ទាំងនៅក្នុងយុទ្ធសាស្ត្រត្រីកោណ ក៏ដូចជានៅក្នុងយុទ្ធសាស្ត្រចតុកោណ នាពេលបច្ចុប្បន្ន ។ គ្រប់គ្នាអាចទទួលស្គាល់ពីការលំបាក ក្នុងការ

កែទំរង់កងយោធពលខេមរភូមិន្ទ នៅក្នុងកាលៈទេសៈមួយដែលសភាពការណ៍មិនសូវអំណោយផល ។ នៅក្នុងខណៈដែលទើបតែងើបចាកផុតពីសង្គ្រាម ដំណើរការកែទំរង់ជួបប្រទះនឹងឧបសគ្គឥតឈប់ឈរ រួមទាំងបញ្ហាធំៗមួយចំនួន ដូចជាកង្វះខាតធនធានរចនាសម្ព័ន្ធមិនទាន់សមស្រប ការិយាធិបតេយ្យស្មុគ្រស្មាញ បញ្ហាជំរុំជំរក និងជីវភាពរស់នៅរបស់យោធិន ជាដើម ។ល។

តែទោះជាយ៉ាងណាក៏ដោយ កងយោធពលខេមរភូមិន្ទសំរេចបាននូវជោគជ័យមួយចំនួនធំនៅក្នុងដំណើរការកែទំរង់របស់ខ្លួន ។ ក្រៅពីការធានាបាននូវសុខសន្តិភាពជូនប្រទេសជាតិ កងយោធពលខេមរភូមិន្ទរួមចំណែកយ៉ាងសកម្មនៅក្នុងការស្តារហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការជួយសង្គ្រោះប្រជាពលរដ្ឋនៅពេលជួបគ្រោះមហន្តរាយ និងនៅដើមខែមេសា ឆ្នាំ២០០៦នេះ មានការរួមចំណែកនៅក្នុងបេសកកម្មសន្តិភាពអន្តរជាតិ ។ កិត្យានុភាពរបស់ព្រះរាជាណាចក្រកម្ពុជា កាន់តែលេចធ្លោថែមទៀតនៅលើឆាកអន្តរជាតិ នៅពេលដែលកុលបុត្រខ្មែរជាងមួយរយនាក់ កំពុងបូជាកំលាំងកាយចិត្ត ដើម្បីបុព្វហេតុមនុស្សធម៌ និងដើម្បីភាពសុខសាន្តនៃប្រទេសជាតិមួយនៅក្នុងទ្វីបអាហ្វ្រិក ។ បេសកកម្មរបស់យើងមិនមែនចប់ត្រឹមប្រទេសស៊ូដង់ប៉ុណ្ណោះទេ ។ ថ្វីត្បិតតែសមត្ថភាព និងធនធានរបស់កងយោធពលខេមរភូមិន្ទមានកំរិត កម្ពុជានឹងបន្តខិតខំចូលរួមជាមួយអង្គការសហប្រជាជាតិ នៅក្នុងបេសកកម្មរក្សាសន្តិភាព មានលក្ខណៈជាមនុស្សធម៌ផ្សេងៗទៀតទៅថ្ងៃអនាគត ។

បើទោះជាមានការជឿនលឿនគួរជាទីមោទន នៅក្នុងដំណើរការកែទំរង់របស់ខ្លួនក៏ដោយ ក៏កងយោធពលខេមរភូមិន្ទនៅមានកិច្ចការធំៗជាច្រើនទៀតដែលត្រូវបំពេញដោយអនុលោមទៅតាមវិធានការយុទ្ធសាស្ត្រទាំងឡាយ ដែលមានចែងនៅក្នុងជំពូកបន្តបន្ទាប់ នៃឯកសារសៀវភៅ ស ការពារជាតិ ឆ្នាំ២០០៦ នេះ ។ ដូចអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់សម្តេចនាយករដ្ឋមន្ត្រីពីខាងដើម ដែលថា "សៀវភៅ ស ការពារជាតិ គឺជាត្រីវិស័យសំរាប់កងយោធពលខេមរភូមិន្ទ ក្នុងការអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល នៅលើវិស័យការពារជាតិ ឱ្យបានសំរេចជោគជ័យជាស្ថាពរ ។"

"ព្រះរាជាណាចក្រកម្ពុជា គឺជាប្រទេសជាតិមួយប្រកបដោយសន្តិភាពពេញលេញ ទទួលស្គាល់ដោយអន្តរជាតិទាំងមូល បាន និងកំពុងធ្វើសមាហរណកម្មចូលទៅក្នុងសហគមន៍អន្តរជាតិ ព្រមទាំងកំពុងខិតខំជំរុញឱ្យមានការអភិវឌ្ឍន៍នៅគ្រប់វិស័យ" ម



*សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន អញ្ជើញជាអធិបតីភាព នៅក្នុងពិធីជូនដំណើរកងអនុសេនាធំដោះមីនលេខ១០០៥ ដែលត្រូវចេញទៅបំពេញបេសកកម្មមនុស្សធម៌របស់អង្គការសហប្រជាជាតិ នៅប្រទេសស៊ូដង់ កាលពីថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៦ ។*

# ជំពូកទី ១
# ការពិនិត្យឡើងវិញ នូវនយោបាយការពារជាតិ នៃសៀវភៅ ស ការពារជាតិ ឆ្នាំ២០០០

## គោលដៅនៃកិច្ចការពារជាតិ:

នយោបាយរបស់រាជរដ្ឋាភិបាល នៅក្នុងសៀវភៅ ស ការពារជាតិ ឆ្នាំ២០០០ បានកំណត់យកការធ្វើឱ្យមានសន្តិសុខ និងការអភិវឌ្ឍន៍ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។ គោលដៅនេះ ត្រូវបានកំណត់ឡើងដោយផ្អែកលើកត្តាបីធំៗគឺ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល និងការសន្និដ្ឋានទៅលើការគំរាមកំហែងមកលើសន្តិសុខរបស់ប្រទេសជាតិ ដោយទាមទារឱ្យមានការធានា និងការរួមចំណែកយ៉ាងពេញទំហឹងពីសំណាក់កងយោធពលខេមរភូមិន្ទ ។

- កងយោធាត្រូវទទួលខុសត្រូវទាំងស្រុង ចំពោះការរារាំង និងទប់ទល់ជាមួយនឹងការគំរាមកំហែងណាមួយពីខាងក្រៅ ត្រូវការពារឱ្យបាននូវបូរណភាពទឹកដី ហើយក៏ត្រូវរួមចំណែកនៅក្នុងការធានាឱ្យបាននូវស្ថិរភាព សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម ផងដែរ ។

- ដើម្បីជួយរាជរដ្ឋាភិបាល នៅក្នុងកិច្ចខិតខំប្រឹងប្រែងស្តារ និងកសាងឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធរដ្ឋបាល សេដ្ឋកិច្ច និងសង្គម របស់ប្រទេសជាតិ ជាពិសេសដើម្បីឆ្លើយតបទៅនឹងនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ កងយោធពលខេមរភូមិន្ទមានកាតព្វកិច្ចរួមចំណែកនៅក្នុងភារកិច្ចនេះ ដោយប្រើប្រាស់នូវសមត្ថភាព និងធនធានដែលខ្លួនមាន ដូចជាការកសាង និងជួសជុលផ្លូវថ្នល់ ការកសាង និងជួសជុលប្រព័ន្ធធារាសាស្ត្រ និងការដោះមីន ជាដើម ។

- នៅពេលមានគ្រោះមហន្តរាយ ដូចជាទឹកជំនន់ គ្រោះរាំងស្ងួត ឬជំងឺរាតត្បាត កងយោធពលខេមរភូមិន្ទមានកាតព្វកិច្ច ធ្វើកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរពាក់ព័ន្ធទាំងឡាយ ដើម្បីធ្វើការសង្គ្រោះប្រជាពលរដ្ឋ ។

- កសាងសមត្ថភាពបន្ថែមទៀត ដើម្បីចូលរួមទៅក្នុងកិច្ចប្រតិបត្តិការសន្តិភាពអន្តរជាតិ នៅក្នុងក្របខ័ណ្ឌនៃសំណូមពររបស់អង្គការសហប្រជាជាតិ ។



*នៅចំពោះមុខសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន តំណាងអង្គការសហប្រជាជាតិ ប្រគល់ទង់ជូនតំណាងកងយោធពលខេមរភូមិន្ទ ដែលជាសក្ខីភាពនៃការចាប់ផ្តើមបំពេញបេសកកម្មសន្តិភាព និងមនុស្សធម៌ នៅបរទេសជាលើកដំបូង របស់កងយោធពលខេមរភូមិន្ទ ។*

ផ្តើមចេញពី គោលដៅយុទ្ធសាស្ត្រនេះហើយ ដែលគោលការណ៍មួយចំនួន ត្រូវបានកំណត់ឡើង សំរាប់កងយោធពលខេមរភូមិន្ទ យកទៅអនុវត្ត ។ គោលការណ៍ទាំងនោះ រួមមានការកំណត់ឡើងនូវអាទិភាព នៃកិច្ចការពារជាតិ យុទ្ធសាស្ត្រយោធាតួនាទីបួនយ៉ាង របស់កងយោធពលខេមរភូមិន្ទ និងវិធានការណ៍យុទ្ធសាស្ត្រ មួយចំនួន ដើម្បីធានាឱ្យបាននូវសន្តិភាព ស្ថិរភាព សន្តិសុខសង្គម និងការអភិវឌ្ឍន៍របស់ប្រទេសជាតិ ។

វត្ថុបំណងម្យ៉ាងទៀតរបសយុទ្ធសាស្ត្រនេះ គឺផ្សារភ្ជាប់កងទ័ពជាមួយសហគមន៍ប្រជាពលរដ្ឋ ។ ដូចប្រសាសន៍របស់សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ដែលថា "កង

យោធពលខេមរភូមិន្ទត្រូវស្មោះត្រង់ដាច់ខាតចំពោះបុព្វហេតុជាតិ គោរពរដ្ឋធម្មនុញ្ញ មានវិន័យសីលធម៌ស្អាតស្អំ សុភាពរាបសារ គោរពស្រឡាញ់ប្រជាពលរដ្ឋ មានវិន័យថ្លៃថ្នូរ និងមានសមត្ថភាពគ្រប់គ្រាន់ដើម្បីបំពេញភារៈកិច្ចការពារឯករាជ្យជាតិ អធិបតេយ្យភាព បូរណភាពទឹកដី ថែរក្សាពង្រឹង សន្តិភាព ស្ថិរភាព និងសន្តិសុខសណ្តាប់ធ្នាប់សង្គម ។



យោធិននៃកងយោធពលខេមរភូមិន្ទ តែងតែយកចិត្តទុកដាក់នៅក្នុងការជួយដល់ការងាររបស់ប្រជាពលរដ្ឋ នៅក្នុងតំបន់ដែលខ្លួនទទួលខុសត្រូវ ។ ឯកឧត្តម នាយឧត្តមសេនីយ៍ មាស សុភា អគ្គមេបញ្ជាការរង និងជាមេបញ្ជាការកងទ័ពជើងគោក ដឹកនាំនាយទាហាន នាយទាហានរង ចុះជួយស្ទូងស្រូវប្រជាពលរដ្ឋ ។

ជាទូទៅ គោលដៅយុទ្ធសាស្ត្រនេះមានលក្ខណៈផ្តោតការយកចិត្តទុកដាក់សំខាន់ទៅលើការថែរក្សា និងពង្រឹងសន្តិភាព ស្ថិរភាព និងសន្តិសុខសង្គម និងជំរុញឱ្យកងយោធពលខេមរភូមិន្ទមានការជាប់ពាក់ព័ន្ធកាន់តែច្រើនឡើងថែមទៀត នៅក្នុងភារកិច្ចកសាង និងអភិវឌ្ឍន៍ប្រទេសជាតិ នៅក្នុងពេលក្រោយសង្គ្រាម និយាយរួមគឺធានាឱ្យបាននូវសេចក្តីប្តេជ្ញាចិត្តក្នុងការទប់ទល់នឹងការគំរាមកំហែងពីខាងក្រៅ និងពង្រឹងសន្តិសុខផ្ទៃក្នុង ។

## អាទិភាពនៃកិច្ចការពារជាតិ:

ការកំណត់អាទិភាពនៅក្នុងវិស័យការពារជាតិ គឺជាកត្តាគន្លឹះក្នុងការរៀបចំផែនការយុទ្ធសាស្ត្រ និងធ្វើឱ្យការអនុវត្តន៍ផែនការយុទ្ធសាស្ត្រទាំងឡាយនោះ បានសំរេច

គោលដៅប្រកបដោយប្រសិទ្ធិភាព ។ ការកំណត់អាទិភាពនេះ ក៏ជួយបង្កភាពងាយស្រួលដល់ការអនុវត្តន៍តួនាទី និងភារកិច្ច របស់យោធិននៃកងយោធពលខេមរភូមិន្ទ គ្រប់ៗរូបផងដែរ ។ លើសពីនេះទៅទៀត ការអនុវត្តន៍បានខ្ជាប់ខ្ជួនទៅតាមការកំណត់អាទិភាព អាចជួយធានាឱ្យមានតម្លាភាព និងប្រសិទ្ធិភាព នៅក្នុងការប្រើប្រាស់ធនធាន ជាពិសេសថវិការដ្ឋនៅក្នុងវិស័យការពារជាតិ ។



ដោយសភាពការណ៍សន្តិសុខពិភពលោកមានការប្រែប្រួលយ៉ាងច្រើន ក្រោយខែកញ្ញា ឆ្នាំ២០០១ រាជរដ្ឋាភិបាលកម្ពុជាបានពិនិត្យកែសំរួលឡើងវិញនូវនយោបាយការពារជាតិ ដែលមានចែងនៅក្នុងសៀវភៅ ស ការពារជាតិ ឆ្នាំ២០០០ ដើម្បីឆ្លើយតបឱ្យបានជាវិជ្ជមាន ទៅនឹងសភាពការណ៍សន្តិសុខជាក់ស្តែង ។ នៅក្នុងឯកសារពិវេចនាលើយុទ្ធសាស្ត្រការពារជាតិ ដែលចេញផ្សាយជាផ្លូវការនៅឆ្នាំ២០០២ គោលនយោបាយប្រឆាំងភេរវកម្មអន្តរជាតិត្រូវបានបង្កើតឡើង ដោយដាក់បញ្ចូលជាគោលដៅមួយ នៅក្នុងចំណោមគោលដៅយុទ្ធសាស្ត្រទាំងឡាយដែលកំពុងអនុវត្ត ។ ជាមួយនេះដែរ ដើម្បី

ឱ្យការអនុវត្តន៍គោលការណ៍ទាំងឡាយរបស់សៀវភៅ ស ការពារជាតិ ឆ្នាំ២០០០ កាន់តែទទួលជោគជ័យថែមទៀត ឯកសារវិវេចនាលើយុទ្ធសាស្រ្តការពារជាតិ ឆ្នាំ២០០២ បានផ្តល់នូវអនុសាសន៍មួយចំនួន ដែលក្នុងនោះអាទិភាពនៃកិច្ចការពារជាតិត្រូវបានកំណត់ឡើងវិញ ដោយផ្តោតទៅលើទិដ្ឋភាពចំបងមួយចំនួន ដូចជា:

- ពង្រឹងសមត្ថភាពការពារព្រំដែន ទប់ទល់នឹងសកម្មភាពឧក្រិដ្ឋឆ្លងកាត់ព្រំដែន ការជ្រៀតចូលនៃក្រុមភេរវករ និងបង្កើនការរួមចំណែកក្នុងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងសហគមន៍ តាមបណ្តោយព្រំដែន ។
- ពង្រីកសមត្ថភាពរបស់កងទ័ពជើងទឹក ក្នុងផ្នែកបច្ចេកវិជ្ជា និងធនធាន ដើម្បីធ្វើឱ្យការងារល្បាតការពារព្រំដែនទឹក មានប្រសិទ្ធិភាព ។
- ពន្លឿនការកែទំរង់កងទ័ព ជាពិសេសនៅក្នុងការកាត់រំសាយ ការលើកស្ទួយជីវភាពរស់នៅរបស់កងទ័ព ការកែសំរួលកងឯកភាព និងការកែសំរួលប្រព័ន្ធហ៊ីកហ្វឺន ។
- ការបង្កើតឱ្យមាននូវយន្តការកសាងកំលាំងទ័ពឱ្យបានឆាប់ ដើម្បីធានាដល់និរន្តរភាព និងគុណភាពរបស់កងទ័ព ។
- បង្កើនការចូលរួមចំណែកក្នុងការងារអភិវឌ្ឍន៍ជាតិ ជាពិសេសនៅក្នុងការងារវិស្វកម្ម កិច្ចប្រតិបត្តិការជួយសង្គ្រោះ ការបង្ក្រាប និងបំបាត់ចរាចរអាវុធធុនស្រាលខុសច្បាប់ ការរួមចំណែកនៅក្នុងការថែរក្សាបរិស្ថាន ជាពិសេសទប់ស្កាត់ការកាប់បំផ្លាញព្រៃឈើ ការដាំដើមឈើឡើងវិញ និងសកម្មភាពមនុស្សធម៌ផ្សេងៗទៀត ។
- កសាងសមត្ថភាពជាបណ្តើរ សំរាប់ចូលរួមក្នុងកិច្ចសហប្រតិបត្តិការនៅក្នុងតំបន់ និងអន្តរជាតិ ជាពិសេសចូលរួមចំណែកខ្នាតតូច នៅក្នុងកិច្ចប្រតិបត្តិការសន្តិភាពរបស់អង្គការសហប្រជាជាតិ នៅថ្ងៃអនាគត ។

ការផ្លាស់ប្តូរអាទិភាពនៃកិច្ចការពារជាតិនេះ ពុំបានធ្វើឱ្យរំខានដល់ដំណើរការនៃការអនុវត្តន៍គោលការណ៍យុទ្ធសាស្ត្រណាមួយឡើយ ។ ផ្ទុយទៅវិញ វាជាការផ្តល់នូវគោលការណ៍ថ្មីៗប្រកបដោយភាពប្រាកដនិយមបន្ថែមទៀត ដើម្បីឱ្យស្របទៅតាមសភាពការណ៍ និងតំរូវការជាក់ស្តែង ហើយដែលអាចធ្វើឱ្យកងយោធពលខេមរភូមិន្ទអាចជំនះលើឧបសគ្គនានាបាន ។

## យុទ្ធសាស្ត្រយោធា:

ផ្អែកលើការសន្និដ្ឋានអំពីការគំរាមកំហែងទាំងឡាយ មកលើសន្តិសុខនៃព្រះរាជាណាចក្រកម្ពុជា និងដើម្បីឆ្លើយតបទៅនឹងគោលការណ៍យុទ្ធសាស្រទាំងឡាយ ដែលបានកំណត់ ទាំងនៅក្នុងសៀវភៅ ស ការពារជាតិ ឆ្នាំ២០០០ ក៏ដូចជានៅក្នុងឯកសារវិវេចនាលើយុទ្ធសាស្ត្រការពារជាតិ ឆ្នាំ២០០២ នោះ យុទ្ធសាស្ត្រយោធាមួយត្រូវបានរៀប



អគ្គភាពមនុស្សយោធាប្រចាំព្រះរាជាណាចក្រកម្ពុជា ធ្វើទស្សនកិច្ចសិក្សានៅការិយាល័យសម្របសម្រួលព្រំដែនកម្ពុជា-ថៃ នៅស្រុកប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ។

ចំឡើង ដោយឈរលើគោលការណ៍ " ការតបតប្រកបដោយភាពបត់បែន និងមានការត្រួតពិនិត្យ " ។ យុទ្ធសាស្ត្រនេះ គឺជាគោលជំហរដ៏សមស្របមួយ ដែលប្រទេសកម្ពុជា ជាពិសេសកងយោធពលខេមរភូមិន្ទ ត្រូវប្រកាន់យក នៅក្នុងកាលៈទេសៈដែលប្រទេសជាតិ

ទើបរួចចាកផុតពីសង្គ្រាម និងនៅក្នុងស្ថានភាពដែលកងយោធពលខេមរភូមិន្ទកំពុងធ្វើការកែទម្រង់ និងអភិវឌ្ឍសមត្ថភាពរបស់ខ្លួន ។ ម្យ៉ាងទៀត យុទ្ធសាស្ត្រនេះកំពុងបម្រើយ៉ាងពិតប្រាកដ ដល់នយោបាយរបស់រាជរដ្ឋាភិបាល នៅក្នុងការបង្រួបបង្រួមជាតិ នយោបាយសន្តិភាពនិយមជាមួយប្រជាជាតិជិតខាងខ្លួន ព្រមទាំងសុឆន្ទៈ និងកិច្ចខិតខំប្រឹងប្រែងដើម្បីធ្វើសមាហរណកម្មឱ្យកាន់តែជ្រៅ ទៅក្នុងសហគមន៍អន្តរជាតិ ។

សន្តិសុខខាងក្រៅរបស់ប្រទេសកម្ពុជា ពឹងផ្អែកជាចំបងទៅលើការពង្រឹងសន្តិសុខផ្ទៃក្នុង ដែលជាការធានាបាននូវឯកភាពជាតិ ស្ថិរភាពនយោបាយ និងកំណើនសេដ្ឋកិច្ច ។ តែទោះជាយ៉ាងណាក៏ដោយ ការជ្រើសរើសយកការចរចារនៅក្នុងនយោបាយសន្តិភាពនិយមរបស់ប្រទេសកម្ពុជា ពុំមែនជាការរារាំងមិនឱ្យមានការពង្រឹងវត្តមានកងយោធានៅតាមបណ្តោយព្រំដែននោះទេ ។ ថ្វីត្បិតតែកម្ពុជាជាប្រទេសតូចមានសមត្ថភាពផ្នែកយោធាមិនសូវរឹងប៉ឹងយ៉ាងណាក៏ដោយ យើងរក្សាសិទ្ធិធ្វើការតបតជាដាច់ខាត នៅពេលណាដែលមានការឈ្លានពានពីខាងក្រៅ ហើយប្រតិកម្មនេះនឹងធ្វើឡើងដោយមានការត្រួតត្រាហ្មត់ចត់ និងប្រកបដោយការអត់ធ្មត់ ។ ទោះបីជាមានវិធានការយោធានៅក្នុងកាលៈទេសៈបែបនេះក្តី ភាពបត់បែនផ្សេងៗទៀតនឹងត្រូវយកមកប្រើ ដើម្បីឈានទៅរកដំណោះស្រាយដោយសន្តិវិធី ។

## លទ្ធផលនៃការអនុវត្តន៍ផែនការយុទ្ធសាស្ត្រ:

នៅក្នុងរយៈពេល ៥ឆ្នាំ (២០០១-២០០៥) កន្លងមកនេះ យើងឃើញមានការរីកចំរើនមួយចំនួនទៅ ក្នុងការអនុវត្តន៍ផែនការយុទ្ធសាស្ត្រ ដែលកំណត់ឡើងដោយសៀវភៅ ស ការពារជាតិ និងផែនការប្រាំឆ្នាំរបស់កងយោធពលខេមរភូមិន្ទ ។ តែទោះជាយ៉ាងណាក៏ដោយ គោលដៅយុទ្ធសាស្ត្រសំខាន់ៗខ្លះ នៅពុំទាន់អាចអនុវត្តទៅបាន ឬក៏មានការជឿនលឿនទៅមុខតិចតួច ។ យើងកត់សំគាល់ឃើញចំណុចជាវិជ្ជមាន និងកង្វះខាតមួយចំនួន ដូចខាងក្រោម:

កងយោធពលខេមរភូមិន្ទបានពង្រឹងជាលំដាប់ នូវវិធានការសន្តិសុខនៅតាមព្រំដែន ដោយបានដាក់ពង្រាយកងឯកភាពការពារព្រំដែននៅតាមបណ្តាចំណុចយុទ្ធសាស្ត្រទាំងឡាយ សំដៅធានានូវអធិបតេយ្យភាព និងបូរណភាពទឹកដីរបស់ព្រះរាជាណាចក្រកម្ពុជា ។ កំលាំងការពារព្រំដែននេះមានសារៈសំខាន់ណាស់ នៅក្នុងការធ្វើឱ្យមានជាប្រចាំនូវវត្តមានកំលាំងឃ្លាំមើលព្រំដែន ដើម្បីរារាំងការរំលោភបំពានណាមួយ និងរួមសហការជាមួយស្ថាប័នមានសមត្ថកិច្ចដទៃទៀត ក្នុងការប្រយុទ្ធទល់នឹងសកម្មភាពឧក្រិដ្ឋកម្មឆ្លងដែន ។ កងឯកភាពជួរមុខនេះ អាចធ្វើប្រតិកម្មតបតភ្លាមៗ នៅក្នុងករណីចាំបាច់ណាមួយ ហើយក៏ជាអ្នកប្រមូល និងផ្តល់នូវពត៌មានសំងាត់ សំរាប់បំរើឱ្យការងាររៀបចំផែនការប្រតិបត្តិការសឹក ។ នៅក្រោមនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍន៍សហគមន៍នៅតាមជនបទដាច់ស្រយាល ជាពិសេសនៅតំបន់តាមបណ្តោយព្រំដែន កំលាំងការពារព្រំដែនគឺជារបាំងការពារសន្តិសុខយ៉ាងសំខាន់ តទៅអនាគត ។

តែទោះជាយ៉ាងណាក៏ដោយ កំលាំងការពារព្រំដែនកំពុងជួបប្រទះនឹងការលំបាកមួយចំនួនដូចជា ភូមិសាស្ត្រស្មុគ្រស្មាញ ការខ្វះផ្លូវគមនាគមន៍តាមបណ្តោយព្រំដែន ការខ្វះសមត្ថភាពនៅក្នុងជំនាញឯកទេសផ្សេងៗ ការលំបាកនៅក្នុងការផ្គត់ផ្គង់ និងដឹកជញ្ជូន និងកង្វះខាតកំលាំងសំរាប់ធ្វើការផ្លាស់ប្តូរ ជាដើម ។

ការកែសំរួលកងឯកភាពប្រយុទ្ធពីថ្នាក់កងពលធំ មកនៅត្រឹមកងពលតូច និងការច្របាច់បញ្ចូលគ្នានូវបណ្តាកងពលតូចដែលរៀបរយហើយមួយចំនួន គឺជាជោគជ័យយ៉ាងត្រចះត្រចង់ ។ វិធានការនេះ បានជួយកាត់បន្ថយវិបត្តិចំនួនទ័ពមិនគ្រប់ ធ្វើឱ្យការដឹកនាំបញ្ជាសមស្របទៅនឹងសមត្ថភាពរបស់មេបញ្ជាការកងឯកភាព និងសំរួលដល់ប្រព័ន្ធផ្គត់ផ្គង់ផ្នែកភស្តុភារ និងសំភារៈ ។ម្យ៉ាងទៀត ការរៀបចំឡើងវិញនេះបានបង្ហាញឱ្យឃើញយ៉ាងច្បាស់ នូវការវិវត្តន៍ទៅមុខនៅក្នុងការកែទំរង់កងយោធពលខេមរភូមិន្ទ ។

រាជរដ្ឋាភិបាលសំរេចជោគជ័យបានមួយផ្នែកធំ នៅក្នុងដំណើរការកាត់រំសាយបុគ្គលិកយោធា ។ ថ្វីត្បិតតែចំនួន ១៥០០០នាក់ ដែលបានគ្រោងទុកសំរាប់ដំណាក់ការទីពីរ នៅពុំទាន់បានធ្វើការកាត់រំសាយយ៉ាងណាក៏ដោយ ស្ថិតិដែលមានក្នុងពេលបច្ចុប្បន្ន

បង្ហាញឱ្យឃើញថាមានការកាត់បន្ថយយ៉ាងច្រើន បើប្រៀបធៀបទៅនឹងស្ថិតិមុនឆ្នាំ ១៩៩៩ ដែលមានប្រមាណ ១៦៥០០០នាក់ ។ រាជរដ្ឋាភិបាលមានផែនការនឹងកាត់បន្ថយបុគ្គលិកយោធាជាបន្តទៅទៀត ដែលវិធានការពិស្តារនឹងមានបកស្រាយនៅក្នុងជំពូកក្រោយទៀត ។



*ឥស្សរជនជាន់ខ្ពស់ដែលជាថ្នាក់ដឹកនាំរបស់ក្រសួងការពារជាតិ និងអគ្គបញ្ជាការនៃកងយោធពលខេមរភូមិន្ទ ទទួលបានគ្រឿងឥស្សរិយយស ដែលជាគុណប្រយោជន៍នៅក្នុងកិច្ចខិតខំប្រឹងប្រែងបំរើមាតុភូមិ និងការៈកិច្ចដ៏ខ្ពង់ខ្ពស់របស់ខ្លួន ។*

កងយោធពលខេមរភូមិន្ទ មានប្រព័ន្ធហ្វឹកហ្វឺនកាន់តែប្រសើរឡើងជាលំដាប់ ។ បច្ចុប្បន្ននេះការហ្វឹកហ្វឺនបណ្តុះបណ្តាលយោធិនអាជីព និងការហ្វឹកហ្វឺនជំនាញឯកទេសកំពុងត្រូវបានពង្រឹង ។ ដោយឡែកនៅក្នុងការហ្វឹកហ្វឺនយោធិនអាជីព យើងមានប្រព័ន្ធមួយយ៉ាងត្រឹមត្រូវ គឺចាប់ពីថ្នាក់នាយទាហានសកម្ម ថ្នាក់បញ្ជាការ និងសេនាធិការ រហូតដល់ថ្នាក់យុទ្ធសាស្ត្រ ។ ក៏ប៉ុន្តែ បញ្ហាមានសេសសល់នៅឡើយ ដូចជាគុណភាពនៃការអប់រំនៅមានកំរិត ដោយសារកម្មវិធីសិក្សា និងសមត្ថភាពយោធាចារ្យពុំទាន់មានការជឿនលឿន ការខ្វះខាតមធ្យោបាយសំរាប់ការអប់រំ គោលដៅដែលមកទទួលយកការហ្វឹកហ្វឺនមានគុណសម្បត្តិមិនគ្រប់គ្រាន់ ជាដើម ។

តួនាទីមួយនៅក្នុងចំណោមតួនាទីទាំងបួនរបស់កងយោធពលខេមរភូមិន្ទ គឺរួមចំណែកនៅក្នុងការកសាង និងអភិវឌ្ឍប្រទេសជាតិ ។ កងយោធពលខេមរភូមិន្ទបានប្រើប្រាស់នូវសមត្ថភាព ដែលនៅមានកំរិតនៅឡើយរបស់ខ្លួន ដូចជានៅក្នុងការងារវិស្វកម្ម ការដោះមីន ការជួយសង្គ្រោះ ...។ល។ ដើម្បីជួយរាជរដ្ឋាភិបាលក្នុងការស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងរួមចំណែកនៅក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រទេសជាតិ ។ កងវិស្វកម្មនៃកងយោធពលខេមរភូមិន្ទ សំរេចបាននូវស្នាដៃល្អប្រសើរនៅក្នុងការកសាង និងជួសជុលផ្លូវគមនាគមន៍ និងប្រព័ន្ធធារាសាស្ត្រ រីឯកងឯកភាពពាក់ព័ន្ធមួយចំនួនទៀត មានការប្រុងប្រៀបរួចជាស្រេច ដើម្បីជួយសង្គ្រោះប្រជាពលរដ្ឋនៅពេលជួបគ្រោះមហន្តរាយ ។ ស្ថាប័នសុខាភិបាលក៏មានសកម្មភាពផងដែរ នៅក្នុងការផ្តល់សេវាកម្មខ្នាតតូចសំរាប់ប្រជាពលរដ្ឋ ជាពិសេសនៅតាមសហគមន៍ជនបទ ។



កងឯកភាពវិស្វកម្មរបស់អគ្គបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រួមចំណែកយ៉ាងសកម្មជាមួយរាជរដ្ឋាភិបាល នៅក្នុងការស្តារស្ពាន និងកសាងប្រព័ន្ធផ្លូវគមនាគមន៍ នៅទូទាំងប្រទេស ។ ឯកឧត្តម ឧត្តមសេនីយ៍ឯក គន់ គីម អគ្គមេបញ្ជាការរង នៃ ក.ភ.ម. ចុះត្រួតពិនិត្យការងារជួសជុលផ្លូវ ។

មានការវិវត្តន៍គួរឱ្យចាប់អារម្មណ៍ នៅក្នុងការខិតខំកសាងសមត្ថភាពសំរាប់ប្រឆាំងអំពើភេរវកម្ម ។ ទោះបីជាសមត្ថភាពនេះនៅមានទំហំតូចណាស់ក៏ដោយ ក៏វាបានបង្ហាញអំពីការបោះជំហានយ៉ាងសកម្ម ហើយកំពុងទាក់ទាញចំណាប់អារម្មណ៍ពីសំណាក់

សហគមន៍អន្តរជាតិ ។ រាជរដ្ឋាភិបាលនឹងបន្តយកចិត្តទុកដាក់ ធ្វើការពង្រឹកសមត្ថភាពនេះ នៅពេលអនាគត ដោយសហការជាមួយអន្តរជាតិ ។



*អាវុធដែលប្រើប្រាស់ខុសច្បាប់ ត្រូវបានរឹបអូស និងប្រមូលដោយកងរាជអាវុធហត្ថ នៅក្នុងវិធានការពង្រឹងសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម ។*

កងយោធពលខេមរភូមិន្ទ ជាពិសេសកងរាជអាវុធហត្ថ បានបំពេញតួនាទីយ៉ាងសកម្ម និងយ៉ាងមានប្រសិទ្ធិភាព នៅក្នុងការធានាសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម ។ ពលរដ្ឋគ្រប់រូបអាចធ្វើដំណើរទូទាំងប្រទេសដោយគ្មានការហាមឃាត់ ឬការព្រួយបារម្ភអ្វីឡើយ ។ ជាងនេះទៅទៀតនោះ ការមានសន្តិសុខល្អប្រសើរនៅក្នុងសង្គមជាតិ បានជួយពង្រឹងដល់ដំណើរការកសាងលទ្ធិប្រជាធិបតេយ្យ កំណើនសេដ្ឋកិច្ច កិច្ចប្រឹងប្រែងធ្វើការអភិវឌ្ឍន៍ជនបទ និងស្ថិរភាពនយោបាយ ។

ទោះបីជាមានការវិវត្តន៍ទៅមុខជាដុំកំភួនយ៉ាងណាក៏ដោយ ការខកខានមិនបានអនុវត្ត ឬអនុវត្តមិនបានសំរេចជោគជ័យ នូវវិធានការណ៍យុទ្ធសាស្ត្រសំខាន់ៗមួយចំនួន បានបង្កជាឧបសគ្គដល់កំណែទំរង់កងយោធពលខេមរភូមិន្ទទាំងមូល ។ ឧបសគ្គទាំងនោះអាចបណ្តាលមកពីកត្តាមួយចំនួនដូចជា ការយល់ដឹងអំពីគោលការណ៍យុទ្ធសាស្ត្រនៃនយោបាយការពារជាតិនៅមានកំរិត ឥទ្ធិពលនយោបាយ ព្រមទាំងបញ្ហាធនធាន និង

មធ្យោបាយ ជាដើម ។ នៅក្នុងន័យនេះ យើងគួរទទួលស្គាល់អំពីចំណុចអសកម្មមួយចំនួន ដែលយើងចាំបាច់ត្រូវលើកយកមកកែសំរួលឱ្យបានល្អិតល្អន់ នៅក្នុងជំពូកខាងក្រោយនៃ សៀវភៅ ស ការពារជាតិ ឆ្នាំ២០០៦ នេះ ។ ចំណុចពិសេសទាំងនោះ មានជាអាទិ៍:

- ការកាត់រំសាយកងទ័ពពុំទាន់បានសំរេចគោលដៅជាស្ថាពរ ដោយសារហេតុផលបច្ចេកទេស ។ យើងគប្បីធ្វើការកែតំរូវបញ្ហានេះ រួមបញ្ចូលទាំងការកំណត់ឱ្យបានជាក់លាក់ថែមទៀត នូវគោលដៅចុងក្រោយនៃការកាត់រំសាយ គឺកំណត់រចនាសម្ព័ន្ធឱ្យបានជាក់លាក់ និងកំណត់នូវចំនួនបុគ្គលិកយោធាដែលត្រូវការរក្សាទុក ។
- ថវិកាការពារជាតិមានកំរិតទាប មិនទាន់ឆ្លើយតបគ្រប់គ្រាន់ទៅនឹងសេចក្តីត្រូវការចាំបាច់ ដែលជាអាទិភាពនៃកិច្ចការពារជាតិនៅឡើយទេ ។ កត្តានេះបានធ្វើឱ្យដំណើរការសំខាន់ៗខ្លះនៅក្នុងកំណែទំរង់កងទ័ព ជួបប្រទះការលំបាក ។ ម្យ៉ាងទៀត គ្រឿងយុទ្ធោបករណ៍ទាំងឡាយ មានអាយុកាលយូរយាមកហើយ និងមានការខូចទ្រុឌទ្រោម ដែលភាគច្រើនពុំអាចប្រើប្រាស់បាន ។
- នៅពុំទាន់មានការជឿនលឿននៅឡើយ នៅក្នុងការធ្វើឱ្យជីវភាពរស់នៅរបស់យោធិនមានភាពប្រសើរឡើង ដោយសារកំរិតនៃថវិកាការពារជាតិមិនតុល្យភាពទៅនឹងសេចក្តីត្រូវការរបស់កងទ័ព ។ ការអូសបន្លាយវែងឆ្ងាយតទៅទៀតនៃបញ្ហានេះ នឹងប៉ះពាល់ដល់ការពង្រឹងសមត្ថភាពយោធា និរន្តរភាពនៃកំលាំង ក៏ដូចជាការធ្វើឱ្យមានបច្ច័យមិនល្អសំរាប់ការអនុវត្តន៍ច្បាប់ស្តីពីកាតព្វកិច្ចយោធាផងដែរ ។
- កងទ័ពមានវិន័យខ្ពស់ ទទួលបានការគ្រប់គ្រងល្អ និងមានការត្រៀមលក្ខណៈគ្រប់ពេលវេលាទៅបាន អាស្រ័យដោយការមានបន្ទាយរស់នៅ

ត្រឹមត្រូវ ។ ដូច្នេះការខិតខំកសាងបន្ទាយទ័ពជាបណ្តើរៗ ត្រូវតែយកមក ពិចារណាឱ្យបានដិតដល់ ។

- យើងបានកែសំរួលរចនាសម្ព័ន្ធកងឯកភាពថ្នាក់ក្រោម បានប្រកបដោយ លទ្ធផលល្អ ។ ក៏ប៉ុន្តែរចនាសម្ព័ន្ធខាងលើ ដូចជានៅអគ្គបញ្ជាការ និង ក្រសួងការពារជាតិ ត្រូវឱ្យមានការកែសំរួលថែមទៀត ដើម្បីកាត់បន្ថយ ភាពស្មុគស្មាញនៅក្នុងប្រព័ន្ធការិយាធិបតេយ្យ ។
- ការអនុវត្តន៍ច្បាប់ស្តីពីសោធននិវត្តន៍ មិនទាន់ប្រព្រឹត្តទៅបាន ដែលធ្វើឱ្យ រាំងស្ទះដល់ការផ្ទេរបុគ្គលិកចេញពីជួរកងទ័ព ។
- ការអនុវត្តន៍ច្បាប់ផ្សេងទៀតពាក់ព័ន្ធនឹងករណីយកិច្ចប្រចាំថ្ងៃរបស់យោធិន ក៏ដូចជានីតិវិធីជាមូលដ្ឋាន សំរាប់កិច្ចសហប្រតិបត្តិការវាងអាជ្ញាធរយោធា និងស៊ីវិល ។
- ការកំណត់អំពីតួនាទី និងការទទួលខុសត្រូវ រវាងកំលាំងការពារព្រំដែន នៅ មិនទាន់បានជាក់លាក់នៅឡើយ ។

# ជំពូកទី ២
## ការវិភាគអំពី
## ការគំរាមកំហែងមកលើសន្តិសុខនៃព្រះរាជាណាចក្រកម្ពុជា

### អំពើភេរវកម្មអន្តរជាតិ និងនៅក្នុងតំបន់:

ការគំរាមកំហែងនៃអំពើភេរវកម្មអន្តរជាតិ កំពុងក្លាយជាជំងឺរាតត្បាតយ៉ាងសាហាវ សំរាប់មនុស្សជាតិទាំងមូល ។ ចាប់តាំងពីមានព្រឹត្តិការណ៍ថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ២០០១ មក អំពើភេរវកម្មបានរីករាលដាលស្ទើរគ្រប់ទិសទីនៃពិភពលោកទាំងមូល ។ ការគំរាមកំហែងនេះ បច្ចុប្បន្ននេះវាបានក្លាយទៅជាសង្គ្រាមមួយដែលគ្មានរណសិរ្សពិតប្រាកដ ។ សោកនាដកម្មទាំងឡាយ បានប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើជនស៊ីវិលស្លូតត្រង់ ជាពិសេសស្ត្រី និងកុមារ ។




កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីការពារជាតិរបស់ប្រទេសនៃសមាគមអាស៊ាន បានប្រារព្ធធ្វើឡើងជាលើកដំបូង នៅថ្ងៃទី៩ ខែឧសភា ឆ្នាំ២០០៦ នៅទីក្រុង គូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី ។ កិច្ចប្រជុំនេះ គឺជាវេទិកា [illegible] ។

គ្មានប្រទេសជាតិណាមួយ អាចធ្វើការរារាំងអំពើភេរវកម្មឆ្លងកាត់ព្រំដែនបានដោយឯកឯងទេ តែគេចាំបាច់ត្រូវមានវិធានការការពារ ។ ប្រតិកម្មដែលមានប្រសិទ្ធភាពប្រឆាំងទល់នឹងអំពើភេរវកម្ម ទាមទារឱ្យមានការឆ្លើយតបជាអន្តរជាតិ ដោយឈរលើមូលដ្ឋាននៃកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ ។ កិច្ចសហប្រតិបត្តិការរួមជាអន្តរជាតិមានរួមបញ្ចូលទាំងការផ្លាស់ប្តូរពត៌មានសំងាត់ កិច្ចសហប្រតិបត្តិការបច្ចេកទេស ការជួយគ្នារាំងខ្ទប់ប្រព័ន្ធហិរញ្ញវត្ថុរបស់ភេរវករ ព្រមទាំងសកម្មភាពផ្សេងៗទៀតដែលធ្វើឱ្យភេរវករមិនអាចប្រមូលផ្តុំបាន និងតំបន់ស្ថានសួគ៌សុវត្ថិភាពរបស់ពួកគេត្រូវបានបំផ្លាញជាប់ជានិច្ច ។ ប្រជាជាតិដែលស្នេហាសន្តិភាពនៅលើពិភពលោក ត្រូវតែរួមគ្នាដោយមិនរារែក នៅក្នុងគោលជំហរប្រឆាំងភេរវកម្មអន្តរជាតិ ។

## អំពើភេរវកម្ម និងសន្តិសុខនៃប្រទេសកម្ពុជា:

សភាពការណ៍សន្តិសុខទូទៅនៃព្រះរាជាណាចក្រកម្ពុជា ចាប់ផ្តើមមានស្ថិរភាពតាំងពីមានកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល នៅក្នុងការអនុវត្តន៍នយោបាយឈ្នះ ឈ្នះ ដែលបាននាំឆ្ពោះទៅរកការបញ្ចប់ទាំងស្រុងនូវសង្គ្រាមផ្ទៃក្នុង និងការរលំរលាយជាស្ថាពរ នៃអង្គការចាត់តាំងនយោបាយ និងយោធារបស់ក្រុមខ្មែរក្រហមនៅចុងឆ្នាំ១៩៩៨ ។ តែទោះជាដូច្នេះក្តី ការផ្លាស់ប្តូរយ៉ាងគំហុកនៃសភាពការណ៍សន្តិសុខពិភពលោក ជាពិសេសចាប់តាំងពីមានព្រឹត្តិការណ៍ខែកញ្ញា ឆ្នាំ២០០១ និងការវាយប្រហារភេរវកម្មជាបន្តបន្ទាប់ពាសពេញពិភពលោកមកនោះ បានជំរុញឱ្យប្រទេសកម្ពុជាចាំបាច់ត្រូវប្រកាន់យកនូវវិធានការសន្តិសុខម៉ឺងម៉ាត់មួយចំនួន ដើម្បីទប់ស្កាត់ឱ្យបាននូវមហន្តរាយណាមួយ ដែលអាចកើតឡើងបានជាយថាហេតុ ។

រាជរដ្ឋាភិបាលបានសំដែងនូវសុឆន្ទៈ ក្នុងកិច្ចរួមសហការយ៉ាងពេញទំហឹងជាមួយសហគមន៍អន្តរជាតិ នៅក្នុងចំណាត់ការទប់ស្កាត់អំពើភេរវកម្ម តាំងពីដើមរៀងមក ។ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា ក៏បានចេញ

នូវសេចក្តីថ្លែងការជាបន្ទាន់មួយ ថ្កោលទោសយ៉ាងពេញទំហឹងចំពោះការវាយប្រហារដ៏ព្រៃផ្សៃនៅលើកោះបាលី ប្រទេសឥណ្ឌូណេស៊ី កាលពីខែតុលា ឆ្នាំ២០០២ ។ នៅក្នុងខែឧសភា ឆ្នាំ២០០៣ អាជ្ញាធរកម្ពុជាទប់ស្កាត់បានទាន់ពេលវេលា នូវការប៉ុនប៉ងបង្កើតបណ្តាញភេរវកម្ម ហ្សាមីអា អ៊ីស្លាមីយ៉ា (ហ្សេអាយ) ដោយបានចាប់ខ្លួនសមាជិកក្រុមនេះមួយចំនួន ។ នៅក្នុងកិច្ចប្រជុំប្រមុខដឹកនាំប្រទេសអាស៊ាន កាលពីខែមិថុនា ឆ្នាំ២០០៣ ឯកឧត្តម ហោ ណាំហុង រដ្ឋមន្ត្រីក្រសួងការបរទេសកម្ពុជា និងឯកឧត្តម អាឡិចហ្សង់ឌ័រដោនន័រ រដ្ឋមន្ត្រីក្រសួងការបរទេសអូស្ត្រាលី បានចុះហត្ថលេខាលើអនុស្សរណៈស្តីពីកិច្ចសហប្រតិបត្តិការប្រឆាំងអំពើភេរវកម្ម ដែលមានរួមបញ្ចូលការផ្លាស់ប្តូរពត៌មានសំងាត់ និងជំនួយផ្នែកបច្ចេកទេសផងដែរ ។



ឯកឧត្តម ហោ ណាំហុង រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា (ស្តាំ) និងឯកឧត្តម Alexander Downer រដ្ឋមន្ត្រីក្រសួងការបរទេសនៃប្រទេសអូស្ត្រាលី (ឆ្វេង) ចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការប្រឆាំងអំពើភេរវកម្មអន្តរជាតិ ។

ដើម្បីលើកស្ទួយសន្តិសុខឱ្យកាន់តែប្រសើរឡើងថែមទៀត នាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជាបានសំរេចជាឧឡារិក ធ្វើការបំផ្លាញចោលទាំងស្រុងនូវប្រព័ន្ធកាំជ្រួចការពារអាកាសដែលបាញ់ចេញពីលើស្មាមនុស្សផុនស្ត្រេឡា២ និងកាំជ្រួចបាញ់ពីដីទៅអាកាស

ផុន អេស អេ ៣ ។ វិធានការនេះ គឺជាផ្នែកមួយនៃការទប់ស្កាត់មិនឱ្យអាវុធប្រភេទនេះធ្លាក់ទៅលើដៃពួកភេរវករ ដែលអាចប្រើប្រាស់ទៅលើគោលដៅផ្សេងៗបានយ៉ាងងាយ ហើយជាងនេះទៅទៀតនោះ គឺជួយធានាដល់សុវត្ថិភាពនៃដំណើរការអាកាសចរណ៍ស៊ីវិល ។



លោកឧត្តមសេនីយ៍ទោ Hindmarsh មេបញ្ជាការទ័ពពិសេសអូស្ត្រាលី ជួបសំណេះសំណាលជាមួយឯកឧត្តម នាយឧត្តមសេនីយ៍ ប៉ុល សារឿន អគ្គមេបញ្ជាការរង និងជានាយកសេនាធិការចំរុះ ខ.ភ.ម. នៅក្នុងឱកាសធ្វើទស្សនកិច្ចនៅកម្ពុជាដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការផ្នែកប្រឆាំងភេរវកម្ម ។

ទោះបីជាមានចំណាត់ការយ៉ាងមានប្រសិទ្ធិភាពបែបនេះក៏ដោយ កម្ពុជានៅតែចាត់ទុកការគំរាមកំហែងនៃអំពើភេរវកម្មអន្តរជាតិ មកលើសន្តិសុខនៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងការព្រួយបារម្ភកំរិតខ្ពស់នៅឡើយ ។ ប្រទេសកម្ពុជាកំពុងជួបការលំបាកក្នុងការពង្រឹងកិច្ចការពារព្រំដែនគោក និងព្រំដែនសមុទ្រដ៏វែងអន្លាយរបស់ខ្លួន ។ ការខ្វះនូវហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍តាមបណ្តោយព្រំដែន រួមផ្សំនឹងការខ្វះខាតនូវសំភារៈ និងបច្ចេកទេសជំនាញមួយចំនួន អាចជាអំណោយផលសំរាប់ការជ្រៀតចូលរបស់ពួកភេរវករ ។ ជាមួយនេះដែរ សមត្ថភាពរបស់អាជ្ញាធរអនុវត្តន៍ច្បាប់ទាំងឡាយ នៅក្នុងការស៊ើបអង្កេតទៅលើសកម្មភាពរបស់ពួកភេរវករធំៗ នៅមានកំរិតនៅឡើយ ដោយសារកង្វះខាតការហ្វឹកហ្វឺន និងប្រភពធនធាន ។

នៅមានទិដ្ឋភាពដ៏ទៃទៀត ដែលប្រទេសកម្ពុជាត្រូវបង្កើនការយកចិត្តទុកដាក់ដើម្បីទប់ស្កាត់ឱ្យបាននូវការទទួលរងដោយចំពោះ នៃការវាយប្រហារពីសំណាក់អំពើភេរវកម្មអន្តរជាតិ ក្នុងនោះកម្ពុជាកំពុងពិនិត្យមើលយ៉ាងហ្មត់ចត់ អំពីទំនាក់ទំនងរវាងអំពើភេរវកម្ម ការជួញដូរគ្រឿងញៀន និងអន្តោប្រវេសន៍ខុសច្បាប់ ។ តែទោះជាយ៉ាងណាក៏ដោយ កម្ពុជាជាប្រទេសមានអំណោយផលនៅលើទិដ្ឋភាពមួយចំនួន:

- ការខិតខំធ្វើយ៉ាងណា ដើម្បីបញ្ចៀសមិនឱ្យសកម្មភាពភេរវកម្មកើតមានឡើងបាននៅក្នុងព្រះរាជាណាចក្រកម្ពុជា គឺជានយោបាយគន្លឹះ ដែលរាជរដ្ឋាភិបាលតែងតែប្រកាន់យកជានិច្ច ។ នយោបាយនេះ មានរួមបញ្ចូលទាំងការមិនរើសអើងនៅក្នុងមជ្ឈដ្ឋានសាសនា ផងដែរ ។
- ប្រទេសកម្ពុជាមានភ័ព្វសំណាងដោយមានទីតាំងភូមិសាស្ត្រ ស្ថិតនៅដាច់ដោយឡែកពីប្រភពនៃកំសួលភេរវកម្ម ។ ព្រំដែនទាំងអស់របស់ប្រទេស ពុំបានផ្តល់ជារបៀងយុទ្ធសាស្ត្រសំរាប់ជាឈ្នាន់នៃការវាយប្រហារ ជំរកលាក់ខ្លួន ឬក៏បំរើឱ្យការគាំទ្រផ្ទាល់ពីពួកភេរវករបរទេសឡើយ ។ ដូច្នេះ លំហូរចូលមកនៃប្រភពធនធាន កំឡាំងមនុស្ស និងការធ្វើឱ្យមានការគាំទ្រមាំមួននៅក្នុងតំបន់ មានការលំបាកខ្លាំងណាស់ ។ម្យ៉ាងទៀត បណ្តាប្រទេសដែលនៅជុំវិញ សុទ្ធតែមានគោលជំហរប្រឆាំងអំពើភេរវកម្មយ៉ាងម៉ឺងម៉ាត់ដូចគ្នា ។
- ភេរវជនមានការលំបាក ក្នុងការធ្វើកំណែនអ្នកស្ម័គ្រចិត្តធ្វើអត្តឃាត ឬអ្នកបំពេញកិច្ចការភេរវកម្ម នៅក្នុងប្រទេសកម្ពុជា ។ ការធ្វើសកម្មភាពភេរវកម្មនៅក្នុងប្រទេស អាចជួបឧបសគ្គច្រើនសំរាប់កំលាំងដែលនាំចូលពីខាងក្រៅ ។
- ពុំមានសញ្ញាណាមួយ ដែលបង្ហាញឱ្យឃើញពីការដុះដាលនៃគំនិតអ៊ីស្លាមជ្រុលនិយម ហ្សីហាត ឬការប៉ុនប៉ងបំបែករដ្ឋណាមួយឡើយ ។

កំប៉ុន្តែ ទោះជាមានការសន្និដ្ឋានបែបនេះយ៉ាងណាក្តី រាជរដ្ឋាភិបាលកម្ពុជានៅតែមានការព្រួយបារម្ភជានិច្ច ហើយបានប្រុងប្រៀប និងបានចាត់នូវវិធានការមួយចំនួន ដែលមានអធិប្បាយពិស្តារនៅក្នុងជំពូកទី៤ ។

## សន្តិសុខសង្គមៈ

ថ្មីៗនេះ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់លើវិធានការមួយចំនួន ដើម្បីទប់ស្កាត់ និងកាត់បន្ថយគ្រោះថ្នាក់ ដែលបណ្តាលមកពីគ្រឿងញៀន ដែលកំពុងរីករាលដាលពាសពេញផ្ទៃប្រទេសគួរឱ្យព្រួយបារម្ភ ។ ការហូរចូល និងការធ្វើចរាចរឆ្លងកាត់នៃគ្រឿងញៀន ជាពិសេសប្រភេទថ្នាំអាំហ្វេតាមីន កំពុងគំរាមកំហែងយ៉ាងធ្ងន់ធ្ងរដល់សន្តិសុខសង្គមនៃព្រះរាជាណាចក្រកម្ពុជា ហើយមានភាពកាន់តែធ្ងន់ធ្ងរឡើងនៅក្នុងរយៈពេល ៥ឆ្នាំកន្លងមកនេះ គឺតចាប់តាំងពីពេលដែលប្រទេសកម្ពុជាធ្លាប់គ្រាន់តែជាចំណុចឆ្លងកាត់



លោកជំទាវ ប៊ុន រ៉ានី ហ៊ុន សែន ប្រធានកាកបាទក្រហមកម្ពុជា ចុះសួរសុខទុក្ខ និងចែកអំណោយដល់យុវជន ដែលកំពុងទទួលបានសេវាជំនួយព្យាបាលសារធាតុញៀន នៅមជ្ឈមណ្ឌលព្យាបាលសារធាតុញៀនរបស់កងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យ ។

រហូតដល់ក្លាយជាអ្នកចាប់ផ្តើមប្រើប្រាស់ផ្ទាល់ ។ ថ្នាំញៀនកំពុងតែពេញនិយមយ៉ាងខ្លាំងនៅរាជធានីភ្នំពេញ ក្រុងព្រះសីហនុ និងតាមបណ្តាខេត្តចំនួនមួយចំនួនទៀត ជាពិសេសតំបន់

ជាប់ព្រំដែន ។ ក្រុមយុវជន យុវនារីក្មេងៗ ដែលខ្វះការអប់រំ កំពុងតែទទួលរងគ្រោះច្រើនជាងគេ ។ ក្រុមទុច្ចរិតដែលជួញដូរគ្រឿងញៀន កាន់តែមានសមត្ថភាពខ្ពស់ឡើង រីឯអាជ្ញាធរមានសមត្ថកិច្ច កំពុងតែជួបប្រទះការលំបាកផ្នែកមធ្យោបាយ និងសំភារៈសំរាប់ប្រតិបត្តិការ និងទេពកោសល្យនៅឡើយ ។



ឯកឧត្តម ឧត្តមសេនីយ៍ឯក ទាយ សាំងយុន រដ្ឋលេខាធិការក្រសួងការពារជាតិ ( ស្តាំ ) និងលោក David de Beer អ្នកគ្រប់គ្រងកម្មវិធី EU-ASAC ( ឆ្វេង ) ចុះហត្ថលេខាលើអនុស្សារណៈស្តីពីកិច្ចសហប្រតិបត្តិការគ្រប់គ្រងអាវុធធុនតូច និងអាវុធធុនស្រាល

បច្ចុប្បន្ននេះ កម្ពុជាមានការរីកចំរើនច្រើន នៅក្នុងការដោះស្រាយបញ្ហាចរាចរ និងការប្រើប្រាស់អាវុធខុសច្បាប់ ដែលបន្សល់ទុកក្រោយសង្គ្រាម ។ ក្នុងរយៈពេលប៉ុន្មានឆ្នាំមកនេះ កម្ពុជាបានសំដែងនូវសុឆន្ទៈយ៉ាងប្តូរផ្តាច់ ក្នុងការប្រយុទ្ធតស៊ូដើម្បីគ្រប់គ្រងឱ្យបានហ្មត់ចត់នូវអាវុធជាតិផ្ទុះទាំងឡាយ ដោយមានកិច្ចសហការពីសំណាក់សហគមន៍អ៊ឺរ៉ុប ។ អាវុធរាប់សែនដើម ដែលលើសពីសេចក្តីត្រូវការសំរាប់កិច្ចការពារជាតិ និងដែលប្រមូលបានពីការកាន់កាប់ខុសច្បាប់ ត្រូវបានបំផ្លាញចោលជាបន្តបន្ទាប់ នៅក្រោមនយោបាយ " អណ្តាតភ្លើងសន្តិភាព " របស់រាជរដ្ឋាភិបាល ហើយសព្វាវុធដែលទុកប្រើប្រាស់ ត្រូវបានរក្សានៅក្នុងឃ្លាំងសុវត្ថិភាព ។ កម្មវិធីដែលឧបត្ថម្ភដោយសហគមន៍អ៊ឺរ៉ុបនេះ មិនត្រឹមតែផ្តល់អត្ថប្រយោជន៍ដល់សន្តិសុខសង្គមប៉ុណ្ណោះទេ តែក៏ជាផ្នែកមួយ

នៃការជួយអភិវឌ្ឍន៍សហគមន៍ផងដែរ តាមរយៈកម្មវិធីអភិវឌ្ឍន៍ខ្នាតតូច គឺកម្មវិធីលះបង់ការប្រើប្រាស់អាវុធខុសច្បាប់ ដើម្បីប្តូរយកការអភិវឌ្ឍន៍នៅក្នុងសហគមន៍ ។ ការលុបបំបាត់ស្លាកស្នាមនៃសង្គ្រាម ដែលបន្តឆក់យកជីវិតប្រជាពលរដ្ឋរាប់រយនាក់ក្នុងមួយឆ្នាំៗ គឺគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ នៅតែជាអាទិភាពចំបងរបស់រាជរដ្ឋាភិបាលនៅឡើយ ។



អាវុធយុទ្ធភ័ណ្ឌត្រូវបានរក្សាទុកយ៉ាងត្រឹមត្រូវ នៅក្នុងឃ្លាំងសុវត្ថិភាពនានា ពាសពេញផ្ទៃប្រទេស នៅក្រោមកិច្ចសហប្រតិបត្តិការ និងជំនួយរបស់គម្រោងកម្មវិធី EU-ASAC ។

បញ្ហាដីធ្លី ជាប្រភពនៃទំនាស់ នៅក្នុងសង្គម ។ ការផ្តល់ប័ណ្ណកម្មសិទ្ធិត្រឹមត្រូវ ដល់បុគ្គល និងស្ថាប័នផ្សេងៗ រួមទាំង កងយោធពលខេមរភូមិន្ទ ផងដែរ ដោយ ក្រសួងដែនដីនគររូបនីយកម្ម និងសំណង់ នឹងជួយបង្ការ នូវទំនាស់ទាំងនេះ និងរួមចំណែកផងដែរ ក្នុងការធានានូវស្ថិរភាព សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ កងយោធពលខេមរភូមិន្ទ ត្រូវធ្វើជាគំរូនៅក្នុងការចុះបញ្ជីជាផ្លូវការសំរាប់ដីធ្លីដែលខ្លួនកំពុងប្រើប្រាស់ ។

ព្រឹត្តិការណ៍ចាប់កុមារា កុមារីនៅក្នុងសាលារៀនអន្តរជាតិទីក្រុងសៀមរាបកាលពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៥ គឺជាបទពិសោធន៍ដ៏សំខាន់មួយ ។ ថ្វីត្បិតតែសកម្មភាពនេះអាចចាត់ទុកថាជាការចាប់ចំណាប់ខ្មាំងដើម្បីទារប្រាក់ដ៏សាហាវមួយ និងពុំមែនជា

មិនមែនជាភេរវកម្មក៏ដោយ តែគឺជាការដាស់តឿនមួយសំរាប់អនាគត ប្រសិនបើសកម្មភាពហើយនេះជាអំពើភេរវកម្មវិញនោះ ។

## ផលវិបាកផ្នែកភូមិសាស្ត្រ:

ដូចបានសន្និដ្ឋាននៅក្នុងសៀវភៅ ស ការពារជាតិ ឆ្នាំ២000 រួចមកហើយថា គ្មានការកត់សំគាល់ណាមួយ បង្ហាញអំពីការគំរាមកំហែងផ្នែកយោធាពីខាងក្រៅ មកលើព្រះរាជាណាចក្រកម្ពុជា សំរាប់ពេលបច្ចុប្បន្ន ក៏ដូចជានៅក្នុងអនាគតរយ:ពេលខ្លី និងមធ្យម នេះទេ ។ ការសន្និដ្ឋាននេះផ្អែកទៅលើសភាពការណ៍អំណោយផលនៅតាមតំបន់ព្រំដែនទាំងអស់ជុំវិញប្រទេសកម្ពុជា ។ ទោះបីជាមានបញ្ហាខ្លះៗបន្តកើតមាននៅឡើយ ដូចជាភាពមិនច្បាស់លាស់នៃខ្សែបន្ទាត់ព្រំដែន បញ្ហាជនជាតិភាគតិចម៉ុងតាញ៉ា យ៉ាងណាក្តី ការដោះស្រាយជាមួយនឹងអាជ្ញាធរ និងរដ្ឋាភិបាលនៃប្រទេសជិតខាង ត្រូវបានធ្វើឡើង ប្រកបដោយការអត់ធ្មត់ និងមានលក្ខណ:ការទូត ។

វិវាទព្រំដែនជាមួយប្រទេសជិតខាង គឺជាមរតកប្រវត្តិសាស្ត្រដ៏យូរលង់ នងនៅមានបន្តរហូតមកដល់បច្ចុប្បន្ននេះ ។ រាល់ការវិវាទទាំងនេះ ស្តែងចេញពីភាពមិនច្បាស់លាស់នៃខ្សែបន្ទាត់ព្រំដែន និងបញ្ហាផ្សេងៗទៀតដែលបណ្តាលមកពីការធ្វើអជីវកម្មរួមគ្នា និងប្រភពធនធានធម្មជាតិនៅតំបន់សមុទ្រ ។ គ្រប់ពេលដែលមានវិវាទ ប្រទេសកម្ពុជាបានជ្រើសរើសយកការចរចារ ដើម្បីពិភាក្សា និងដោះស្រាយបញ្ហាទាំងនេះ ។ តែទោះជាយ៉ាងណាក៏ដោយ ជំរើសនេះពុំមែនជាការរារាំងមិនឱ្យមានវត្តមានកំលាំងយោធានៅតាមតំបន់ព្រំដែននោះឡើយ ។ ឥទ្ធិពលនៃសង្គ្រាមដែលអូសបន្លាយជាច្រើនឆ្នាំ បានធ្វើឱ្យតំបន់ខ្លះ ជាពិសេសនៅតាមបណ្តាខេត្តជាប់ព្រំដែន មិនស្ថិតនៅក្រោមការគ្រប់គ្រងនៃរដ្ឋបាលតែមួយ ដែលជាហេតុធ្វើឱ្យកម្ពុជាបាត់បង់ការគ្រប់គ្រងព្រំដែនរបស់ខ្លួនអស់មួយរយ: ។ នៅក្នុងករណីនេះ ការចុះហត្ថលេខាលើសន្ធិសញ្ញាបំពេញបន្ថែមលើលិច្ចព្រមព្រៀងកំណត់ព្រំដែនរដ្ឋឆ្នាំ១៩៨៥ ដោយប្រមុខរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង

សាធារណរដ្ឋសង្គមនិយមវៀតណាម គឺជាលទ្ធផលដ៏ត្រចះត្រចង់ជាប្រវត្តិសាស្ត្រ សំរាប់ដំណើរការនៃការកសាងព្រំដែនច្បាស់លាស់រវាងប្រទេសទាំងពីរ តទៅថ្ងៃអនាគត ។



កំលាំងវិស្វករមួយរបស់កងទ័ពជើងគោក មានតួនាទីសំខាន់នៅក្នុងការស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត នៅតាមតំបន់ជនបទដាច់ស្រយាល ជាការរួមចំណែកនៅក្នុងការជួយលើកស្ទួយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ។

គុណភាព និងបរិមាណ នៃផ្លូវគមនាគមន៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាពិសេសប្រព័ន្ធផ្លូវគោក មិនទាន់អាចបំរើឱ្យការធ្វើចរាចរបានងាយស្រួលទាំងស្រុងទូទាំងផ្ទៃប្រទេសនោះទេ ។ ទិដ្ឋភាពនេះ បានបង្កឱ្យមានការរអាក់រអួល ចំពោះកំណើនសេដ្ឋកិច្ច ដែលរមែងប្រទាក់ក្រឡារវាងរាជធានី និងទីប្រជុំជនដទៃទៀតនៅទូទាំងព្រះរាជាណាចក្រ ។ ជារឿយៗ ការផ្លាស់ប្តូរទំនិញសព្វសារពើ ត្រូវបានធ្វើផ្ទាល់ជាមួយប្រទេសជិតខាង ដោយសារមានភាពងាយស្រួលជាង ដែលធ្វើឱ្យផលកំរៃ និងធនធានមនុស្សមួយចំនួនរបូតចេញទៅក្រៅ ។

ដើម្បីធ្វើឱ្យប្រៀបនៃសន្តិសុខផ្ទៃកភូមិសាស្ត្រនៅទូទាំងប្រទេសកម្ពុជា មានភាពប្រសើរឡើងវិញ ចាំបាច់ត្រូវធ្វើឱ្យប្រព័ន្ធដឹកនាំបញ្ជារដ្ឋបាល មានចរន្តចូលទៅដល់តំបន់ជាយដែនគ្រប់ទិសទីទាំងអស់ ។ សកម្មភាពនេះ នឹងបង្កើនការធានានូវអធិបតេយ្យភាព

របស់រដ្ឋ និងធ្វើឱ្យរដ្ឋបាលបាននៅជិតប្រជាពលរដ្ឋជារៀងរហូត ។ ទាំងនេះនឹងប្រព្រឹត្តទៅបានដោយការកសាងហេដ្ឋារចនាសម្ព័ន្ធគ្រប់វិស័យ មានជាអាទិ៍ ផ្លូវថ្នល់ បណ្ដាញទាក់ទងជាតិមាន ព្រមទាំងតំរូវការផ្សេងៗទៀត ដែលធ្វើឱ្យសង្គមនៅទីនោះ បានផ្សារភ្ជាប់ជាអាជ្ញាធរជាមួយរដ្ឋបាលកណ្ដាល ។

## បញ្ហារំខានប្រជាសាស្ត្រ:

ប្រទេសកម្ពុជាមានប្រជាពលរដ្ឋតិច ហើយរស់នៅតាមភូមិសាស្ត្រប្រកបដោយដង់ស៊ីតេឃ្លាតឆ្ងាយ ។ ចំនួនពលរដ្ឋមានប្រមាណជាង ១៣លាននាក់ នាឆ្នាំ២០០៥



*សកម្មភាពរបស់កងយោធពលខេមរភូមិន្ទ នៅក្នុងការចុះជួយបូមទឹកស្រោចដំណាំស្រូវរបស់ប្រជាពលរដ្ឋ នៅពេលកំពុងជួបគ្រោះរាំងស្ងួត ។*

ស្ថិតនៅក្នុងលំដាប់ទាបនៅឡើយ ។ សង្គ្រាម កង្វះខាតហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំងឧបសគ្គគ្រាប់មីន បានធ្វើឱ្យដង់ស៊ីតេនៅតាមតំបន់ព្រំដែនមានកំរិតទាប ។ ស្ថានភាពប្រជាសាស្ត្រនៃប្រទេសកម្ពុជាប្រកបដោយលក្ខណៈមួយចំនួន ដូចជាអវត្តមាននៃជំនាន់

មួយដែលបាត់បង់នៅក្នុងអំឡុងពេលសង្គ្រាម បន្ទុកនៃស្រទាប់យុវវ័យនៅក្រោយសង្គ្រាម ភាពខុសគ្នាខ្លាំងពេកនៃដង់ស៊ីតេប្រជាពលរដ្ឋ និងកំណើននៃនគរូបនីយកម្ម ។

ប្រទេសកម្ពុជាក៏កំពុងជួបប្រទះនឹងបញ្ហាការងារសំរាប់ក្រុមយុវជនយុវនារី ។ រាជរដ្ឋាភិបាលបានខិតខំដើម្បីជំរុញឱ្យមានកំណើននៃការងារនៅតាមជនបទ តាមរយៈ នយោបាយពង្រីកប្រព័ន្ធធារាសាស្ត្រ សំរាប់ការងារបង្កបង្កើនផលកសិកម្មឱ្យបានច្រើន ផង ។ នៅឯទីក្រុងក៏ជួបនឹងបញ្ហាដូចគ្នា ។ កំណើនស្ថិតិនៅក្នុងស្រទាប់យុវវ័យ បានធ្វើឱ្យ រាជរដ្ឋាភិបាលមានការខ្វាយខ្វល់ និងត្រូវបង្កើនការយកចិត្តទុកដាក់ទ្វេឡើងទៀត នៅ ក្នុងការគ្រប់គ្រងការងារ និងការទាក់ទាញវិនិយោគ ។

ដូចដែលបានអធិប្បាយត្រួស១ពីខាងដើម វិបត្តិផ្នែកប្រជាសាស្ត្រមួយចំនួន កំពុង ចោទឡើងសំរាប់សង្គមខ្មែរទាំងមូល ដូចជា អតុល្យភាពនៃការបែងចែកធនធាន ការប្រើ ប្រាស់ដីធ្លីមិនបានបរិបូរ កំរិតនៃការអប់រំនៅទាបតាមតំបន់ជនបទ វិបត្តិជំងឺអេដស៍ វិបត្តិ ការងារជាដើម ។ល។ រាជរដ្ឋាភិបាលកំពុងយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍន៍តំបន់ព្រំដែន តាមរយៈការស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធ និងអភិវឌ្ឍន៍សេដ្ឋកិច្ច ។ កងយោធពល ខេមរភូមិន្ទ គឺជាកំលាំងមួយដ៏សំខាន់ដែលអាចរួមចំណែកក្នុងការសំរេចភារៈកិច្ចនេះ ជា ពិសេសនៅក្នុងតំបន់ព្រំដែនដាច់ស្រយាល និងទីណាដែលប្រកបដោយសំណល់អាក្រក់ នៃសង្គ្រាម ។

### បញ្ហាសេដ្ឋកិច្ចៈ

សព្វថ្ងៃនេះ ប្រទេសកម្ពុជាមានសក្តានុពលផ្នែកសេដ្ឋកិច្ច ដោយពឹងផ្អែកសំខាន់ ទៅលើវិស័យកសិកម្ម ។ ក្រៅពីនេះ ឧស្សាហកម្មវាយនភ័ណ្ឌ វិស័យទេសចរណ៍ និងសំណង់ ក៏កំពុងរីកចំរើនទៅមុខជាលំដាប់ ។ កម្ពុជានាពេលបច្ចុប្បន្ន មានលទ្ធភាពក្នុងការផ្គត់ផ្គង់ ស្បៀងអាហារខ្លួនឯងបានគ្រប់គ្រាន់ ជាពិសេសគឺស្រូវអង្ករ តែនៅតែពឹងផ្អែកជាចំបង លើធាតុអាកាស និងទឹកភ្លៀង ។ ដោយប្រើប្រាស់កំលាំង៧០ភាគរយនៃចំនួនប្រជាពលរដ្ឋ

សកម្ម ប្រទេសកម្ពុជាអាចផលិតផលស្រូវលើសពីសេចក្តីត្រូវការចាប់ពីឆ្នាំ ២០០២មក ហើយតទៅថ្ងៃអនាគត បរិមាណនេះនឹងកើនឡើងទៀត លើកលែងតែមានការជួបប្រទះគ្រោះធម្មជាតិ ។ ប្រទេសកម្ពុជាពុំទាន់បានធ្វើអាជីវកម្មពេញលេញទាំងស្រុងនៅឡើយទេ ចំពោះប្រភពធនធានសំខាន់មួយចំនួនទៀត ដូចជា រ៉ែ កៅស៊ូ ប្រេងកាត ...។ល ។



ស្ពាន និងផ្លូវគមនាគមន៍តាមជនបទ ដែលកសាងដោយកងកំលាំងវិស្វកម្មនៃកងយោធពលខេមរភូមិន្ទ នៅក្នុងការរួមចំណែក [illegible] របស់រាជរដ្ឋាភិបាល ។

ដោយមានជំនួយយ៉ាងសកម្មពីកងកំលាំងប្រដាប់អាវុធ រាជរដ្ឋាភិបាលបានទទួលជោគជ័យនៅក្នុងការកាត់បន្ថយ និងលុបបំបាត់សកម្មភាពរត់ពន្ធ និងការលាងលុយកខ្វក់ ដែលបានញាំញីសេដ្ឋកិច្ចជាតិយ៉ាងធ្ងន់ធ្ងរ ។ កងទ័ពក៏បានរួមចំណែកយ៉ាងសកម្មនៅក្នុងការស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធផ្លូវគមនាគមន៍ ជាពិសេសនៅតាមតំបន់លំបាកៗ មួយចំនួនដូចជាផ្លូវលេខ៥៦ (ពីខេត្តពោធិសាត់ទៅព្រំដែនថៃ) ផ្លូវលេខ៤១ (ពីទីរួមខេត្តកំពង់ស្ពឺទៅស្រុកឱរ៉ាល់) ផ្លូវសំខាន់ៗនៅភាគខាងជើងផ្លូវជាតិលេខ៦ និងនៅក្នុងតំបន់ខាងកើតទន្លេមេគង្គ ជាដើម ។ ទន្ទឹមនឹងនេះ កងទ័ពក៏បានរួមចំណែកនៅក្នុងការស្តារ

ប្រព័ន្ធធារាសាស្ត្រ និងការដោះមីន ដើម្បីផ្តល់លទ្ធភាពច្រើនថែមទៀតដល់ការពង្រីកវិស័យកសិកម្ម និងវិស័យទេសចរណ៍ ។

ការអភិវឌ្ឍន៍សេដ្ឋកិច្ចអាចនឹងប្រព្រឹត្តទៅបាន អាស្រ័យមួយភាគធំទៅលើការមានសន្តិសុខ និងសុវត្ថិភាពសង្គម រួមទាំងស្ថិរភាពនយោបាយផងដែរ ។ ម្យ៉ាងទៀត ការធានាបាននូវសន្តិសុខគ្រប់គ្រាន់ នៅតាមបណ្តារបៀងពាណិជ្ជកម្ម ព្រលានយន្តហោះ និងគមនាគមន៍ផ្លូវសមុទ្រ គឺជាកត្តាស្លាប់រស់នៃកំណើនសេដ្ឋកិច្ច ។

ប៉ុន្មានឆ្នាំកន្លងមកនេះ ពិភពលោក ជាពិសេសនៅបណ្តាប្រទេសមួយចំនួននៅអាស៊ីអាគ្នេយ៍ មានការជ្រួលច្របល់ដោយសារការផ្ទុះឡើងនៃជំងឺរលាកផ្លូវដង្ហើមធ្ងន់ធ្ងរ ឬជំងឺសារស៍ និងជំងឺគ្រុនផ្តាសាយបក្សី ។ វិបត្តិនៃជំងឺនេះ បានធ្វើឱ្យសេដ្ឋកិច្ច ពាណិជ្ជកម្ម និងឧស្សាហកម្ម ទូទាំងពិភពលោក មានភាពរអាក់រអួល ។ បច្ចុប្បន្ននេះ កម្ពុជាបានយកចិត្តទុកដាក់រួមសហការជាមួយសហគមន៍អន្តរជាតិ នៅក្នុងការប្រយុទ្ធជាមួយជំងឺគ្រុនផ្តាសាយបក្សី ដែលកំពុងគំរាមកំហែងនៅស្ទើរគ្រប់ទិសទីពាសពេញពិភពលោក ដោយកម្ពុជាបានចាត់ទុកថាបញ្ហានេះអាចប៉ះពាល់ដល់វិស័យទេសចរណ៍ និងវិនិយោគទុន ។

ជារៀងរាល់ឆ្នាំ ប្រទេសកម្ពុជាបានទទួលការឧបត្ថម្ភគាំទ្រផ្នែកហិរញ្ញវត្ថុពីសំណាក់សហគមន៍អន្តរជាតិ តាមរូបភាពជំនួយឥតសំណង កម្ចី និងតាមរយៈកម្មវិធី និងគំរោងរបស់អង្គការផ្សេងៗ ។ ជំនួយទាំងអស់នេះ មានសារៈសំខាន់បំផុតសំរាប់ស្ថិរភាព និងកំណើនសេដ្ឋកិច្ច សំរាប់លើកដំកើងការអភិវឌ្ឍន៍លើវិស័យផ្សេងៗ និងជាពិសេសដើម្បីកាត់បន្ថយភាពក្រីក្រ ។ តែទោះជាយ៉ាងនេះក្តី ការធ្វើឱ្យជំនួយទាំងអស់នេះភាគច្រើនបំផុតបានទៅដល់គោលដៅ គឺប្រយោជន៍សំរាប់អ្នកក្រីក្រពិតប្រាកដ កំពុងស្ថិតនៅជាបញ្ហានៅឡើយ ។ តាមការស្ទង់មើលរបស់រាជរដ្ឋាភិបាល ក៏ដូចជាមតិអន្តរជាតិមួយចំនួន បានបង្ហាញថា មានផលប្រយោជន៍ប្រមាណត្រឹមតែ ៤០ភាគរយប៉ុណ្ណោះនៃជំនួយ បានទៅដល់ដៃអ្នកក្រីក្រខ្មែរពិតប្រាកដ រីឯផ្នែកដែលនៅសល់ត្រឡប់ទៅបំរើឱ្យ

ផលប្រយោជន៍របស់អ្នកដែលដំណើរការកម្មវិធី ជាពិសេសជនជាតិបរទេស ។ កត្តាចំបង នៅក្នុងបញ្ហានេះគឺភាពយឺតយ៉ាវ នៅក្នុងការផ្ទេរជំនាញផ្សេងៗពីអ្នកជំនាញការបរទេស មកឱ្យបុគ្គលិកក្នុងស្រុក និងការធ្វើឱ្យទូលំទូលាយឡើងនូវដំណើរការកម្មវិធី ឬគំរោង ទាំងឡាយ ដោយអ្នកជំនាញការ និងបុគ្គលិកក្នុងស្រុក ។ ការស្ទង់មើលនេះក៏បានបញ្ជាក់ផងដែរថា មានបុគ្គលិកក្នុងស្រុកកាន់តែច្រើនឡើងហើយ ដែលមានសមត្ថភាពប្រហាក់ប្រហែលនឹងទីប្រឹក្សាបរទេស ហើយការប្រៀបធៀបបានចង្អុលបង្ហាញទៀតថា ទីប្រឹក្សាបរទេសត្រូវការប្រាក់បៀវត្សរ៍ពី ១០ ទៅ១៥ ដង នៃប្រាក់បៀវត្សរ៍ដែលគេអាចផ្តល់ជូនបុគ្គលិកក្នុងស្រុក នៅក្នុងឋានៈដូចគ្នា ។

សន្តិសុខសំរាប់ម្ហូបអាហារ គឺជាកត្តាចាំបាច់ ដែលត្រូវយកមកគិតគូរឱ្យបានដិតដល់ ។ បច្ចុប្បន្ននេះ ប្រទេសកម្ពុជាកំពុងជួបប្រទះនឹងបញ្ហាមួយចំនួន ដូចជាការលួចនាំចូលម្ហូបអាហារដែលខូចគុណភាព ការប្រើសារធាតុគីមីដើម្បីរក្សាទុកម្ហូបអាហារឱ្យបានយូរ ការខ្វះអនាម័យនៅពេលចែកចាយម្ហូបអាហារ ជាដើម ។ រាជរដ្ឋាភិបាលកំពុងយកចិត្តទុកដាក់ពង្រឹងការត្រួតពិនិត្យរបស់អាជ្ញាធរឱ្យបានហ្មត់ចត់ និងអប់រំប្រជាពលរដ្ឋតាមប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ ឱ្យយល់អំពីសារៈសំខាន់នៃសន្តិសុខម្ហូបអាហារ ។

## បញ្ហាបរិស្ថាន:

ទាំងនៅក្នុង និងក្រោយពេលសង្គ្រាម កម្ពុជាទទួលរងនូវការវិនាសនៃសម្បត្តិធម្មជាតិដ៏មានតំលៃរបស់ខ្លួនជាបន្តបន្ទាប់ ។ ក្រៅពីបេតិកភ័ណ្ឌវប្បធម៌ជាតិដែលត្រូវបានគេលួចយកទៅលក់នៅឯបរទេស ភោគផលព្រៃឈើ ជីវចំរុះ និងមច្ឆាជាតិ កំពុងស្ថិតក្រោមការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរ ។ ភាពខូចខាតទាំងនេះ អាចកើតមានបានដោយសារបញ្ហាមួយចំនួនដូចជា កង្វះនូវសន្តិសុខគ្រប់គ្រាន់មួយដែលអាចឱ្យការអនុវត្តន៍ច្បាប់មានប្រសិទ្ធិភាព (សង្គ្រាម និងអសន្តិសុខ) សេដ្ឋកិច្ចទន់ខ្សោយដែលធ្វើឱ្យប្រជាពលរដ្ឋ

ចាំបាច់ត្រូវពឹងផ្អែកលើភោគផលធម្មជាតិច្រើនជាងការផលិត និងអំពើពុករលួយ ដែលបើកផ្លូវឱ្យជនទុច្ចរិត និងបរទេសធ្វើការរុករាន ។

រហូតមកទល់ពេលនេះ ប្រជាពលរដ្ឋខ្មែរនៅពុំទាន់ចាប់អារម្មណ៍លើកង្វះខាតទឹកស្អាតសំរាប់ប្រើប្រាស់នៅឡើយទេ ។ នៅរដូវវស្សា មានទឹកខ្លែងខ្លះនៅពុំមានទឹកគ្រប់គ្រាន់សំរាប់បំរើឱ្យការបង្កបង្កើនផល កំដូចជាសំរាប់បរិភោគផងដែរ ជាពិសេសនៅតាមបណ្តាខេត្តភាគខាងកើត និងខាងត្បូង ។ នៅរដូវប្រាំង ដីស្រែចំការមួយភាគធំត្រូវទុកឱ្យនៅទំនេរចោល ហើយអ្នកស្រុកត្រូវបង្ខំចិត្តចាកចោលភូមិស្រុក មករកការងារនៅឯទីក្រុង ។ ជារៀងរាល់ឆ្នាំ វិបត្តិបរិស្ថាននេះបានបន្ថែមបន្ទុកទៅលើវិបត្តិផ្នែកសង្គម និងប្រជាសាស្ត្រ ។ រាជរដ្ឋាភិបាលនីតិកាលទី៣នៃរដ្ឋសភានេះ បានយកចិត្តទុកដាក់ជាចំបងលើបញ្ហាប្រព័ន្ធធារាសាស្ត្រ ដែលជាវិធីគន្លឹះនៅក្នុងការដោះស្រាយបញ្ហានេះ ។

ធនធានគំរបព្រៃឈើនៅកម្ពុជាត្រូវបានថយចុះពី ៧៣ភាគរយ នៃផ្ទៃដីទូទាំងប្រទេសនៅមុនឆ្នាំ១៩៧០ មកនៅត្រឹម ៦១ភាគរយ នាឆ្នាំ២០០២ ។ ដើម្បីទប់ស្កាត់ការបាត់បង់ព្រៃឈើ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញជាបន្តបន្ទាប់នូវគោលនយោបាយ បទបញ្ជា ប្រកាស និងច្បាប់ស្តីពីព្រៃឈើ ដោយដំណើរការអនុវត្តកំណែទំរង់វិស័យព្រៃឈើដ៏ស៊ីជំរៅមួយ ឆ្ពោះទៅរកការគ្រប់គ្រង ថែរក្សា ការពារ និងប្រើប្រាស់ធនធានព្រៃឈើប្រកបដោយប្រសិទ្ធិភាព ក្នុងឆ្នាំ១៩៩៨ រហូតមកដល់បច្ចុប្បន្ន ។ ប៉ុន្តែបញ្ហាដែលកំពុងប្រឈមមុខនោះ គឺការកាប់រាន ទន្ទ្រាន ដុត ឈូសឆាយដីព្រៃឈើ យកធ្វើជាកម្មសិទ្ធ ជំនួញដីធ្លី និងពង្រីកផ្ទៃដីកសិកម្ម ។ ដើម្បីទប់ស្កាត់សភាពការណ៍នេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវបទបញ្ជាស្តីពីការទប់ស្កាត់ បង្ក្រាប និងលុបបំបាត់ ការកាប់រានការដុត ការឈូសឆាយ និងការហ៊ុំព័ទ្ធកាន់កាប់ដីព្រៃឈើ ដែលត្រូវការនូវការចូលរួម និងកិច្ចសហប្រតិបត្តិការពីអជ្ញាធរដែនដី និងស្ថាប័នពាក់ព័ន្ធទាំងអស់ ដោយបានបង្កើតឱ្យមានគណៈកម្មាធិការជាតិ និងអនុគណៈកម្មាធិការខេត្ត ក្រុង ដែលមានអភិបាលខេត្ត ក្រុង ជាអ្នកដឹកនាំអនុវត្តផ្ទាល់ ។

# ជំពូកទី ៣
# យុទ្ធសាស្ត្រ ឆ្នាំ២០០៦

## គ្របខ័ណ្ឌនៃយុទ្ធសាស្ត្រ ឆ្នាំ២០០៦:

ការរៀបចំយុទ្ធសាស្ត្រថ្មី ដើម្បីជំរុញឱ្យមានការវិវត្តន៍ទៅមុខនៅក្នុងដំណើរការកែទំរង់កងទ័ព និងការធានានូវសមត្ថភាពនៃកិច្ចការពារជាតិ ពឹងផ្អែកជាចំបងទៅលើការពិចារណាលើកត្តាមួយចំនួនដូចខាងក្រោម:

**ធនធាន:** ថវិកាសំរាប់កិច្ចការការពារជាតិ កំពុងស្ថិតក្នុងភាពមានកំរិតជាទីបំផុត បើប្រៀបធៀបទៅនឹងតំរូវការនានានៅក្នុងការកែទំរង់ និងអភិវឌ្ឍន៍កងយោធពលខេមរភូមិន្ទ ។ ប្រមាណ ៦១ភាគរយ នៃថវិកាទាំងមូលត្រូវបានប្រើប្រាស់ សំរាប់តែទៅលើប្រាក់បៀវត្សរ៍ដែលមានកំរិតទាបបំផុតតែប៉ុណ្ណោះ រីឯថវិកាប្រមាណ ៣៦ភាគរយទៀត ត្រូវបានចាត់ចែងសំរាប់ស្បៀងអាហារ ប្រេងឥន្ធនៈ និងយោធបរិក្ខាផ្សេងៗ ។ ដូច្នេះសំណល់ថវិកាដ៏ស្តួចស្តើងនេះ ពុំអាចឆ្លើយតបទាំងស្រុងទៅនឹងតំរូវការធំៗជាច្រើនទៀត ដូចជាការកាត់បន្ថយបុគ្គលិកយោធា ការសាងសង់បន្ទាយទ័ព ការជួសជុលថែទាំសំភារៈយោធា ការហ្វឹកហ្វឺន និងការរៀបចំកសាងសមត្ថភាពសំរាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ ជាដើម ។

ដើម្បីនិរន្តរភាពនៃការអភិវឌ្ឍន៍កងកំលាំង ការរក្សានូវកញ្ចប់ថវិកាការពារជាតិដែលមានប្រមាណ ២.៧ ភាគរយនៃផលិតផលសរុប សំរាប់រយៈពេល ៥ឆ្នាំតទៅមុខទៀត ត្រូវតែយកមកពិចារណា ។ ចំណាត់ការនេះ នឹងផ្តល់លទ្ធភាពសំរាប់ឱ្យមានការជឿនលឿនទៅមុខនៅក្នុងការកែទំរង់កងយោធា នៅពេលដែលមានការរីកដុះដាលនៃកំណើនសេដ្ឋកិច្ចជាតិ និងចំនួនបុគ្គលិកកងយោធពលខេមរភូមិន្ទត្រូវបានកាត់បន្ថយជាលំដាប់ ។ ការដកយកថវិកាចេញពីថវិកាការពារជាតិ នៅរាល់ពេលដែលមានការកាត់រំសាយបុគ្គលិកយោធា ពុំបានផ្តល់ឱកាសឱ្យមានការជឿនលឿននៅក្នុងការកែទំរង់នោះឡើយ ។ ម្យ៉ាងវិញទៀត ស្ថាប័នការពារជាតិនៅតែពុំមានលទ្ធភាពខ្លួនឯង ក្នុងការ

អនុវត្តន៍នយោបាយយុទ្ធសាស្ត្រមួយចំនួនរបស់រាជរដ្ឋាភិបាល ជាពិសេសនៅក្នុងការកាត់បន្ថយទំហំកងយោធា ជាដើម ។ តែទោះជាយ៉ាងណាក៏ដោយ ការប្រើប្រាស់ និងគ្រប់គ្រងថវិកាការពារជាតិឱ្យស្របទៅតាមអាទិភាព និងប្រកបដោយតម្លាភាព គឺជាកត្តាគន្លឹះដែលអនុសាសន៍មួយចំនួន នឹងត្រូវបានលើកឡើងនៅជំពូកក្រោយទៀត ។

**ឥទ្ធិពលនយោបាយ:** សន្តិភាព ស្ថិរភាពនយោបាយ និងការលូតលាស់ផ្នែកសេដ្ឋកិច្ច កំពុងផ្តល់នូវឱកាសដ៏ប្រពៃសំរាប់ការកសាង និងអភិវឌ្ឍន៍សមត្ថភាពកងយោធពលខេមរភូមិន្ទ ។ ភក្តីភាពរបស់កងទ័ពចំពោះប្រទេសជាតិ ពឹងផ្អែកជាចំបងផងដែរ ទៅលើអព្យាក្រឹត្យភាពរបស់កងយោធា ។ នៅក្នុងកាលៈទេសៈដែលប្រទេសជាតិកំពុងមានសន្តិភាពពេញលេញ និងស្ថិរភាពនយោបាយកំពុងល្អប្រសើរ ការធ្វើឱ្យកងកំលាំងប្រដាប់អាវុធមិនស្ថិតនៅក្រោមឥទ្ធិពលនយោបាយ នឹងជួយជំរុញឱ្យមានឱកាសកាន់តែច្រើនឡើង នៅក្នុងការកសាងទំនុកទុកចិត្ត និងការគោរពស្រឡាញ់ពីសំណាក់ប្រជាពលរដ្ឋ និងលទ្ធភាពកាន់តែច្រើនសំរាប់វិបុលភាពផ្នែកសេដ្ឋកិច្ច ។

ការធានាបានទាំងស្រុងនូវសន្តិភាព អធិបតេយ្យភាព បូរណភាពទឹកដី និងការរក្សាឱ្យបានស្ថិតស្ថេរនូវស្ថិរភាពផ្ទៃក្នុង ទាមទារឱ្យមានការបណ្តុះបណ្តាលជាប់ជានិច្ចនូវឧត្តមគតិស្នេហាជាតិនៅក្នុងចំណោមបុគ្គលិកនៃកងកំលាំងប្រដាប់អាវុធគ្រប់មជ្ឈដ្ឋាន ។ ឧត្តមគតិនេះ នឹងកើតមាន ហើយរីកចំរើនឡើងបាន អាស្រ័យដោយសុឆន្ទៈផ្នែកនយោបាយរបស់សង្គមជាតិទាំងមូល ជាពិសេសគោលជំហរអព្យាក្រឹត្យពិតប្រាកដ ដែលត្រូវប្រកាន់យកដោយកងកំលាំងប្រដាប់អាវុធ ។ គោលការណ៍សំរាប់កសាងអព្យាក្រឹត្យភាពរបស់កងទ័ព នឹងមានបរិយាយពិស្តារនៅក្នុងផ្នែកក្រោយទៀតនៃឯកសារនេះ ។

**និន្នាការអន្តរជាតិ:** ការស្រូបយកការជួយឧបត្ថម្ភពីសំណាក់សហគមន៍អន្តរជាតិ សំរាប់ការអភិវឌ្ឍន៍កងយោធពលខេមរភូមិន្ទ គឺជាកត្តាពុំអាចខ្វះបាន ។ ជាមួយនេះដែរ កងយោធពលក៏មានកាតព្វកិច្ចក្នុងការខិតខំកសាងកិត្យានុភាពរបស់ខ្លួននៅលើឆាកអន្តរជាតិ ដែលការងារនេះអាចសំរេចទៅបានដោយការធ្វើសមាហរណកម្មបន្តិច

ម្តង១ ។ ដំណើរការកែទំរង់កងយោធពលខេមរភូមិន្ទក្នុងពេលបច្ចុប្បន្ន បានបង្ហាញឱ្យឃើញនូវសេចក្តីត្រូវការចាំបាច់ នៃកិច្ចសហប្រតិបត្តិការជាប់ជានិច្ចជាមួយប្រទេសជាមិត្ត



នៅក្នុងខែឧសភា ឆ្នាំ២០០៦ កម្ពុជាបានធ្វើជាម្ចាស់ផ្ទះ នៅក្នុងការរៀបចំសិក្ខាសាលាស្តីពីការប្រើប្រាស់ភាសាអង់គ្លេសថ្នាក់តំបន់ សំរាប់កងទ័ព ក្រោមកិច្ចសហការរវាងក្រសួងការពារជាតិនៃព្រះរាជាណាចក្រកម្ពុជា និងប្រទេសអូស្ត្រាលី ។ សិក្ខាសាលានេះ ស្ថិតក្រោមអធិបតីភាព ឯកឧត្តម ឧត្តមសេនីយឯក នាង ផាត (រូបកណ្តាលជួរមុខ) រដ្ឋលេខាធិការក្រសួងការពារជាតិ ។

និងស្ថាប័នអន្តរជាតិនានា នៅក្នុងវិស័យធំៗមួយចំនួន ដូចជាការកាត់បន្ថយទំហំកងទ័ព ការបណ្តុះបណ្តាលធនធានមនុស្ស ការអភិវឌ្ឍន៍ផ្នែកបច្ចេកវិទ្យា ការរួមគ្នាដើម្បីប្រយុទ្ធប្រឆាំងទល់នឹងឧក្រិដ្ឋកម្ម និងភេរវកម្មអន្តរជាតិ ការរួមចំណែកនៅក្នុងកិច្ចប្រតិបត្តិការជួយសង្គ្រោះពហុជាតិ ជាដើម ។

នៅក្នុងន័យនេះ កងយោធពលខេមរភូមិន្ទចាំបាច់ត្រូវខិតខំពង្រីកជាលំដាប់នូវកិច្ចសហប្រតិបត្តិការជិតស្និទ្ធជាមួយបណ្តាមជ្ឈដ្ឋានអន្តរជាតិ ដោយមិនប្រកាន់និន្នាការ តាមរយៈការកសាងទំនាក់ទំនងល្អប្រសើរ ទំនុកទុកចិត្ត និងស្មារតីយោគយល់គ្នា ។ ជាមួយនេះដែរ វិធានការយុទ្ធសាស្ត្រទាំងឡាយ ត្រូវតែរៀបចំឱ្យបានហ្មត់ចត់ ប្រកបដោយភាពប្រាកដនិយម និងមានតម្លាភាព ។

## គោលដៅយុទ្ធសាស្ត្រ ឆ្នាំ២០០៦:

នៅពេលដែលប្រទេសជាតិទើបតែបានចាកផុតពីសង្គ្រាម នយោបាយការពារជាតិរបស់ព្រះរាជាណាចក្រកម្ពុជា ផ្តោតការយកចិត្តទុកដាក់តែទៅលើការងារពង្រឹងសន្តិភាព ស្ថិរភាពផ្ទៃក្នុង និងការអភិវឌ្ឍន៍ប្រទេសជាតិ ។

ដូចបានរំលឹកឡើងវិញនៅក្នុងជំពូកមុនរួចមកហើយ គោលដៅសំខាន់ពីរនៅក្នុងនយោបាយការពារជាតិរបស់រាជរដ្ឋាភិបាល គឺការធ្វើឱ្យមានសន្តិសុខស្ថិតស្ថេរយូរអង្វែង និងការកសាងឱកាសសំរាប់ការអភិវឌ្ឍន៍ប្រទេសជាតិ ហើយកងយោធពលខេមរភូមិន្ទកំពុងអនុវត្តនូវវិធានការយុទ្ធសាស្ត្រទាំងឡាយ ដើម្បីឱ្យបានសំរេចជាស្ថាពរនូវគោលដៅទាំងនេះ ។ ក្របខ័ណ្ឌយុទ្ធសាស្ត្រថ្មីចាប់ពីឆ្នាំ២០០៦ តទៅ តំរូវឱ្យមានការពិចារណាលើ



ឧត្តមសេនីយ៍ចូលនិវត្តន៍ John Sanderson (រូបទី៤ពីឆ្វេង) អតីតមេបញ្ជាការកងកំលាំង UNTAC និងបច្ចុប្បន្នជាអគ្គរដ្ឋទូតសុឆន្ទៈរបស់អង្គការ Austcare ជួបសំដែងការគួរសមជាមួយឯកឧត្តម ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ (រូបកណ្តាល) ក្នុងពេលធ្វើទស្សនកិច្ចនៅកម្ពុជា ដើម្បីពិនិត្យមើលការងារដោះមីននៅតំបន់ព្រំដែនភាគពាយ័ព្យនៃប្រទេសកម្ពុជា ។

លទ្ធភាពនៃការធ្វើការងារបន្ថែមទៀត នៅពេលដែលកងយោធពលខេមរភូមិន្ទកំពុងបោះជំហានទៅមុខ នៅក្នុងការអភិវឌ្ឍន៍សមត្ថភាពរបស់ខ្លួន ពោលគឺភារកិច្ចចាំបាច់ដទៃទៀតក្រៅពីការងារផ្ទៃក្នុង ។ ស្របតាមការវិវត្តន៍នៃនិន្នាការសន្តិសុខពិភពលោក និងក្រៅពីការធ្វើឱ្យមានសន្តិសុខ និងការអភិវឌ្ឍន៍សំរាប់ប្រទេសជាតិ កងយោធពល

ខេមរភូមិន្ទត្រូវមានករណីយកិច្ចមួយផ្សេងៗទៀត គឺការចូលប្រឡូកនៅក្នុងកិច្ចការអន្តរជាតិ ។ ដូច្នេះគោលដៅថ្មីនៃកិច្ចការពារជាតិគឺ **សន្តិសុខ ការអភិវឌ្ឍន៍ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ** ។

**សន្តិសុខ:** ដូចដែលបានកំណត់នៅក្នុងឯកសារសៀវភៅ ស ការពារជាតិឆ្នាំ២០០០រួចមកហើយ កងយោធពលខេមរភូមិន្ទមានការទទួលខុសត្រូវលើការធានាឱ្យមានសន្តិភាព ស្ថិរភាព និងសណ្តាប់ធ្នាប់សង្គម សំរាប់ប្រទេសជាតិទាំងមូល ។ វិធានការយុទ្ធសាស្ត្រទាំងឡាយ ត្រូវតែអនុវត្តប្រកបដោយប្រសិទ្ធិភាព ដើម្បីធានាឱ្យបានទាំងស្រុងនូវឱកាសសំរាប់ការស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ។

វិធានការការពារព្រំដែនត្រូវឱ្យមានប្រសិទ្ធិភាពជាប់ជានិច្ច ទោះជាក្នុងកាលៈទេសៈណាក៏ដោយ ។ ព្រំដែននៃប្រទេសកម្ពុជាបានទទួលរងការគំរាមកំហែង និងបាត់បង់ការគ្រប់គ្រងនៅក្នុងអំឡុងពេលសង្គ្រាម ដែលមូលហេតុសំខាន់បណ្តាលមកពីកង្វះខាតឯកភាពផ្ទៃក្នុង និងអវត្តមានកងកំលាំងការពារព្រំដែន ។ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ជាពិសេសបន្ទាប់ពីមានការបង្រួបបង្រួមជាតិ និងការសាបសូន្យទាំងស្រុងនៃក្រុមបំបែកខ្លួន កិច្ចការពារព្រំដែនត្រូវបានពង្រឹងឡើងវិញជាលំដាប់ ។ ភាពមិនប្រក្រតីរវាងប្រទេសជិតខាងកើតមានជាបន្តបន្ទាប់ ដូច្នេះវត្តមានជាក់ស្តែងនៃកងកំលាំងប្រដាប់អាវុធនៅតាមព្រំដែន គឺជាកត្តាស្លាប់រស់ក្នុងការធ្វើឱ្យមាននៅស្ថិតស្ថេរជា រៀងរហូតនៃអធិបតេយ្យភាព និងបូរណភាពទឹកដី ។ លើសពីនេះទៅទៀត វត្តមាននេះជំរុញឱ្យមានការផ្លាស់ប្តូរពាណិជ្ជកម្មប្រកបដោយសន្តិសុខ និងលទ្ធភាពនៃការអភិវឌ្ឍន៍សហគមន៍ប្រជាពលរដ្ឋនៅតាមតំបន់ព្រំដែន ផងដែរ ។

ការធានាឱ្យបាននូវស្ថិរភាព សុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម គឺជាកត្តាស្លាប់រស់ សំរាប់ការរីកចំរើនផ្នែកសេដ្ឋកិច្ច ទេសចរណ៍ និងវិនិយោគ ។ កងយោធពលខេមរភូមិន្ទរួមចំណែក ក្នុងការធ្វើឱ្យមានសន្តិសុខនៅគ្រប់ទិសទីទាំងអស់ទូទាំងប្រទេសជាតិ ។

**ការអភិវឌ្ឍន៍:** គ្មានកាលៈទេសៈ ឬទីណាមួយ ដែលការអភិវឌ្ឍន៍អាចប្រព្រឹត្តទៅបាន ដោយគ្មានសន្តិសុខនោះទេ" ។ កងយោធពលខេមរភូមិន្ទបានបំពេញនូវតួនាទីរបស់ខ្លួន ក្នុងការធ្វើឱ្យប្រជាពលរដ្ឋរស់នៅប្រកបដោយភាពសុខដុមរមនា និងប្រកបមុខរបរដោយសេរី ដើម្បីរួមចំណែកនៅក្នុងការលើកស្ទួយសេដ្ឋកិច្ចជាតិ ។ ទន្ទឹមគ្នានឹងភារកិច្ចការពារជាតិ កងទ័ពក៏បាន និងបន្តរួមចំណែកនៅក្នុងការកសាងជាតិ តាមរយៈការប្រើប្រាស់នូវសមត្ថភាពរបស់ខ្លួន ដូចជាការដោះមីន ការងារស្ពានថ្នល់ និងប្រព័ន្ធធារាសាស្ត្រ ការជួយសង្គ្រោះ ជាដើម ។

**កិច្ចសហប្រតិបត្តិការអន្តរជាតិ:** គោលដៅនៃកិច្ចសហប្រតិបត្តិការអន្តរជាតិ ស្របគ្នាទៅនឹងនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការធ្វើសមាហរណកម្មប្រទេសកម្ពុជា ទៅក្នុងសហគមន៍អន្តរជាតិ ។ ចាប់ពីពេលនេះតទៅ កងយោធពលខេមរភូមិន្ទ ត្រូវតែសកម្មថែមទៀត ក្នុងការចូលប្រឡូក នៅក្នុងឆាកអន្តរជាតិ ដែលជាសកម្មភាពសំខាន់មួយ នៅក្នុងការលើកស្ទួយកិត្យានុភាពរបស់ខ្លួន ។ ការពង្រឹង កិច្ចសហប្រតិបត្តិការអន្តរជាតិ មិនត្រឹមតែជា ការងារកសាងទំនាក់ទំនងល្អ ឬពង្រឹង សម្ព័ន្ធភាពរវាង





*នាយទាហាន ខ.ភ.ម. និងនាយទាហានមកពីបណ្ដាប្រទេសផ្សេងទៀត កំពុងទទួលការហ្វឹកហ្វឺនជំនាញអ្នកសង្កេតការយោធាអង្គការសហប្រជាជាតិ នៅក្នុងប្រទេសម៉ុងហ្គោលី ។*

ប្រទេសនិងប្រទេសប៉ុណ្ណោះទេ តែជាការសំដែងឱ្យឃើញនូវសុឆន្ទៈរបស់យើង នៅក្នុងបុព្វហេតុលើកស្ទួយសន្តិភាព ស្ថិរភាព និងការការពារផលប្រយោជន៍ទៅវិញទៅមក រវាងប្រជាជាតិជិតខាង និងនៅក្នុងតំបន់ជាមួយគ្នាផងដែរ ។ មាត្រា ៥៣ របស់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក៏បានចែងច្បាស់ផងដែរ អំពីសិទ្ធិនៃការចូលរួមរបស់កងយោធាខ្មែរ នៅក្នុងក្របខ័ណ្ឌនៃសំណូមពររបស់អង្គការសហប្រជាជាតិ ។

## យុទ្ធសាស្ត្រយោធា ឆ្នាំ២០០៦:

សៀវភៅ ស ការពារជាតិ ឆ្នាំ២000 បានកំណត់នូវយុទ្ធសាស្ត្រយោធាមួយដោយ ឈរលើគោលជំហរនៃ "ការតបតប្រកបដោយភាពបត់បែន និងមានការត្រួតពិនិត្យ" ។ យុទ្ធសាស្ត្រនេះ តំរូវឱ្យកងយោធពលខេមរភូមិន្ទ ធ្វើការឆ្លើយតបឱ្យបានទាន់ពេលវេលា និងស្របទៅតាមសភាពការណ៍ជាក់ស្តែង ទៅនឹងសកម្មភាពទាំងឡាយណាដែលគំរាមកំហែងដល់សន្តិសុខ និងផលប្រយោជន៍របស់ប្រទេសជាតិ ។ តែទោះជាយ៉ាងណាក៏ដោយ ឥរិយាបទរបស់យើងត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យយ៉ាងហ្មត់ចត់ ព្រមទាំងប្រកាន់យកនូវភាពអត់ធ្មត់ ជាប់ជានិច្ច ។

ការអនុវត្តន៍នូវយុទ្ធសាស្ត្រនេះនៅក្នុងរយៈពេលកន្លងមក ឃើញថាបានទទួលលទ្ធផលជាវិជ្ជមាន ព្រមទាំងធានាបាននូវនិរន្តរភាពនៃសន្តិភាព និងស្ថិរភាពសង្គមបានយ៉ាងល្អប្រសើរ ។ ដូច្នេះ ប្រទេសកម្ពុជាត្រូវប្រកាន់យកនូវយុទ្ធសាស្ត្រនេះជាបន្តទៅទៀតលុះត្រាណាមានការចាំបាច់ថាត្រូវធ្វើការផ្លាស់ប្តូរ ។

លំដាប់ទាំងបីនៃប្រព័ន្ធការពារជាតិ ដែលមានថ្នាក់យុទ្ធសាស្ត្រ ថ្នាក់យុទ្ធនាការ និងថ្នាក់យុទ្ធវិធី គឺជាស្នូលនៃការពង្រឹងយុទ្ធសាស្ត្រយោធានេះ ។ ផ្អែកតាមពិសោធន៍នៅក្នុងរយៈពេលកន្លងមក កងយោធពលខេមរភូមិន្ទត្រូវយកចិត្តទុកដាក់បន្ថែមទៀតទៅលើគោលការណ៍មួយចំនួនដូចមានចែងនៅក្នុងជំពូកក្រោយ ។

## អាទិភាពសំរាប់កិច្ចការពារជាតិ ឆ្នាំ២០០៦:

សៀវភៅ ស ការពារជាតិ ឆ្នាំ២០០០ និងឯកសារវិវេចនាលើយុទ្ធសាស្ត្រការពារជាតិ ២០០២ បានកំណត់ជាលំដាប់លំដោយនូវអាទិភាពមួយចំនួន ក្នុងគោលបំណងជំរុញឱ្យមានប្រសិទ្ធិភាព និងការជឿនលឿន នៅក្នុងដំណើរការកែទំរង់កងយោធពលខេមរភូមិន្ទ ។ ទោះជាជួបប្រទះឧបសគ្គខ្លះៗក៏ដោយ ការកំណត់នូវអាទិភាពទាំងនេះ បាននាំមកនូវលទ្ធផលជាវិជ្ជមាន សំរាប់ការអនុវត្តន៍គោលការណ៍យុទ្ធសាស្ត្រនៅក្នុងរយៈពេលកន្លងមកនេះ ។ អនុលោមទៅតាមការវិវត្តន៍របស់សភាពការសន្តិសុខអន្តរជាតិ និងតំរូវការជាក់ស្តែងនៅក្នុងដំណើរការកែទំរង់កងយោធពលខេមរភូមិន្ទ នៅក្នុងរយៈពេល ៥ឆ្នាំ (២០០៦-២០១០) ខាងមុខ យើងគប្បីធ្វើការពិនិត្យឡើងវិញអំពីការកំណត់អាទិភាពសំរាប់កិច្ចការពារជាតិ តាមរយៈអនុសាសន៍មួយចំនួនដូចតទៅ:



*សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន អញ្ជើញជាអធិបតី នៅក្នុងពិធីបិទសិក្ខាសាលាបូកសរុបលទ្ធផលការងារ ៥ឆ្នាំ (២០០០-២០០៤) និងទិសដៅ ៥ឆ្នាំបន្ត (២០០៥-២០០៩) របស់កងយោធពលខេមរភូមិន្ទ នៅក្រសួងការពារជាតិ ។*

- ត្រូវមានការកែទំរង់បន្ថែមទៀតនៅក្នុងស្ថាប័នការពារជាតិទាំងមូល ។ ការកែទំរង់ចាំបាច់ផ្តោតលើការកែសំរូលរចនាសម្ព័ន្ធយោធាគ្រប់ជាន់ថ្នាក់ ការ

ធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធការិយាធិបតេយ្យ និងប្រព័ន្ធច្បាប់ ហើយចាំបាច់ត្រូវធ្វើការកែសំរួលប្រព័ន្ធដឹកនាំបញ្ជា ភស្តុភារ និងហិរញ្ញវត្ថុផងដែរ ។

- ពង្រឹងវិធានការការពារព្រំដែនឱ្យកាន់តែមានប្រសិទ្ធិភាពថែមទៀត ដោយធានាឱ្យមាននូវវត្តមានអចិន្ត្រៃយ៍របស់កងកំលាំងដែលប្រដាប់ដោយគ្រឿងបំពាក់សមស្រប នៅតាមព្រំដែនទាំងអស់ ។ និរន្តរភាពនៃកំលាំងនេះត្រូវតែរក្សាឱ្យបាន ដោយវិធានការមួយចំនួន ដែលនឹងត្រូវបកស្រាយពិស្តារនៅក្នុងជំពូកក្រោយទៀត ។
- ពិនិត្យ និងរៀបចំឡើងវិញនូវការប្រើប្រាស់ និងការគ្រប់គ្រងធនធានការពារជាតិ សំដៅឱ្យការប្រើប្រាស់បានចំគោលដៅ មានតម្លាភាព និងស្របទៅតាមផែនការអាទិភាព ។
- លៃលកធនធានសមស្របមួយ ដើម្បីធ្វើការស្រោចស្រង់ស្ថានភាពទ្រុឌទ្រោមនៃគ្រឿងយុទ្ធោបករណ៍ ឬក៏ធ្វើការបំពាក់ថ្មីបើអាចធ្វើទៅបាន ជាពិសេសសំភារៈយោធារបស់កងទ័ពជើងគោក និងនាវារបស់កងទ័ពជើងទឹក ដែលយើងត្រូវការដោយខានមិនបាន សំរាប់កិច្ចការពារព្រំដែនគោក និងតំបន់សមុទ្រ ។
- ការសាងសង់បន្ទាយទ័ពគឺជាការចាំបាច់ ដើម្បីឱ្យកងឯកភាពបានទទួលការគ្រប់គ្រងហ្មត់ចត់ ។ ការកសាងនេះ ត្រូវធ្វើជាបណ្តើរៗ ហើយបន្ទាយត្រូវសាងនៅលើភូមិសាស្ត្រអំណោយផល ។
- ត្រូវមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត នៅក្នុងការអភិវឌ្ឍន៍កងកំលាំងរួមទាំងការកំណត់ទំហំរបស់កងយោធពលខេមរភូមិន្ទ ការអនុវត្តន៍ច្បាប់កាតព្វកិច្ចយោធានិងប្រព័ន្ធច្បាប់យោធាទំនើប រួមមានច្បាប់សោធននិវត្តន៍ និងក្រមវិន័យកងទ័ព ជាដើម ក៏ដូចជាការបណ្តុះបណ្តាលធនធានមនុស្ស និងការធ្វើឱ្យបានប្រសើរឡើងនូវជីវភាពរស់នៅរបស់យោធិន ។

- កសាងបណ្ដើរៗនូវសមត្ថភាពប្រឆាំងភេរវកម្ម ដោយប្រឹងប្រែងស្រូបទាញការឧបត្ថម្ភគាំទ្រពីសហគមន៍អន្តរជាតិ ។
- ពង្រឹងសមត្ថភាពមួយចំនួន ដែលត្រូវយកទៅប្រើប្រាស់នៅក្នុងកិច្ចប្រតិបត្តិការសន្តិភាពអន្តរជាតិ ។

- សមត្ថភាពផ្នែកពេទ្យ ក៏ត្រូវតែពង្រឹងផងដែរ ដើម្បីឱ្យកងយោធពលខេមរភូមិន្ទអាចរួមចំណែកបាន នៅក្នុងកិច្ចប្រតិបត្តិការអន្តរជាតិ នៅក្នុងក្របខ័ណ្ឌនៃកិច្ចប្រតិបត្តិការយោធានៅក្នុងវិស័យមនុស្សធម៌ ។ សមត្ថភាពនេះក៏អាចយកមកប្រើប្រាស់នៅក្នុងស្រុកបានដែរ នៅក្នុងការផ្ដល់សេវាពេទ្យជាមូលដ្ឋាន រួមមានការសង្គ្រោះបន្ទាន់ និងការអប់រំសាធារណជនឱ្យយល់ដឹងអំពីអនាម័យ ។

ជោគជ័យនៃអាទិភាពដែលបានពោលខាងដើម ទាមទារឱ្យមានការរៀបចំផែនការហ្មត់ចត់ជាពិសេសផែនការ៥ឆ្នាំ (២០០៦-២០១០) បន្តទៀតរបស់កងយោធពលខេមរភូមិន្ទ សេចក្ដីប្ដេជ្ញាខ្ពស់របស់ថ្នាក់ដឹកនាំក្នុងការអនុវត្តនីតិវិធានការ ភាពត្រឹមត្រូវនៃការប្រើប្រាស់ និងគ្រប់គ្រងថវិកាការពារជាតិ និងការត្រួតពិនិត្យជាប់ជានិច្ច ។

## តួនាទីរបស់កងយោធពលខេមរភូមិន្ទ:

ដូចបានកំណត់រួចមកហើយ កងយោធពលខេមរភូមិន្ទមានតួនាទីចំបងបួនយ៉ាងគឺ ១. ការពារប្រទេស និងផលប្រយោជន៍ជាតិ ២. ធានាសន្តិសុខ សុវត្ថិភាព និងសណ្ដាប់ធ្នាប់សង្គម ៣. រួមចំណែកនៅក្នុងការកសាងជាតិ និង ៤. បង្កើនកិច្ចសហប្រតិបត្តិការអន្តរជាតិ ។ តួនាទីសំខាន់ទាំងនេះ នឹងត្រូវប្រគល់ជូនកងយោធពលខេមរភូមិន្ទជាបន្តទៅទៀត ដោយហេតុថា វាមានភាពសមស្របយ៉ាងពិតប្រាកដទៅនឹងគោលដៅថ្មីនៃកិច្ចការពារជាតិរបស់ព្រះរាជាណាចក្រកម្ពុជា គឺ **សន្តិសុខ ការអភិវឌ្ឍន៍ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ** ។